# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៨៤ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពី

### ការកែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានឋានៈស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខាប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការប្តូរឈ្មោះ នាយកដ្ឋានជលផលទៅជារដ្ឋបាលជលផល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-** ត្រូវបានកែសម្រួល និងដំឡើងអង្គភាព ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដូចខាងក្រោម :

- កែសម្រួល អគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន
- ដំឡើងរដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន
- ដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម
- កែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ

## ជំពូកទី ២

## អំពីបេសកកម្ម តួនាទីភារកិច្ច និង រចនាសម្ព័ន្ធ

### ផ្នែកទី ១

### អគ្គលេខាធិការដ្ឋាន

**មាត្រា ២.-** អគ្គលេខាធិការដ្ឋាន មានភារកិច្ចធ្វើលេខាធិការឱ្យក្រសួង លើការងារ:

- សម្របសម្រួល តាមដាន និងរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងទទួលបន្ទុក នូវសកម្មភាពគ្រប់ផ្នែករបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាពថ្នាក់កណ្តាល អង្គភាពមូលដ្ឋាន និងគ្រឹះស្ថានសាធារណៈចំណុះក្រសួង ដើម្បីសំរេចគោលដៅ និងធានានិរន្តរភាព សង្គតិភាព និងប្រសិទ្ធភាព ក្នុងការបំពេញបេសកកម្ម និងក្នុងការអនុវត្តភារកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សម្របសម្រួលលើការងារទំនាក់ទំនងរបស់ក្រសួងជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធដទៃ
- រៀបចំឯកសារជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងចាត់ចែង គ្រប់គ្រង ចរាចរឯកសារឱ្យចំទិស ធានាឱ្យថ្នាក់ដឹកនាំក្តាប់បានពីការសម្រេចរបស់ក្រសួង
- សម្របសម្រួល លើការងារពិធីការ និងចាត់ចែងគ្រប់គ្រងសន្តិសុខសណ្តាប់ធ្នាប់ក្រសួង
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូបមានថ្នាក់ស្មើអគ្គនាយក និងអមដោយអគ្គលេខាធិការរងមួយចំនួនមានថ្នាក់ស្មើអគ្គនាយករង ជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ២

## រដ្ឋបាលព្រៃឈើ

**មាត្រា ៣.-** រដ្ឋបាលព្រៃឈើ មានបេសកកម្មដូចតទៅ :

- ធានានូវការគ្រប់គ្រងព្រៃឈើ ប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំង ការអភិរក្សជីវចំរុះ និងមរតកវប្បធម៌
- ធានាដល់ការគ្រប់គ្រង និងអភិវឌ្ឍសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ប្រកបដោយនិរន្តរភាព ដែលពាក់ព័ន្ធវិស័យព្រៃឈើ ជីវចំរុះ សត្វព្រៃ និងទីជំរក
- រៀបចំអភិវឌ្ឍ និងអនុវត្តកម្មវិធីព្រៃឈើជាតិ និងផែនការគ្រប់គ្រងព្រៃឈើជាតិ សំរាប់ដំណើរការគ្រប់គ្រង និងអភិវឌ្ឍវិស័យ ព្រៃឈើកម្ពុជា ប្រកបដោយចីរភាព
- អភិវឌ្ឍ និង អនុវត្តកម្មវិធីស្រាវជ្រាវ ការពារ អភិរក្ស និង អភិវឌ្ឍធនធានព្រៃឈើ ជីវចំរុះ សត្វព្រៃ និងទីជំរក

**មាត្រា ៤.-** រដ្ឋបាលព្រៃឈើមានតួនាទីភារកិច្ច ធ្វើជាសេនាធិការឱ្យក្រសួង លើការងារដូចតទៅ:

- គ្រប់គ្រងនិងអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ដែលជាមន្ត្រីរាជការនៃរដ្ឋបាលព្រៃឈើទូទាំងប្រទេស
- សិក្សា ប្រមូលទិន្នន័យលើព្រៃឈើគ្រប់ប្រភេទ ទាក់ទងនឹងកត្តាវិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដើម្បី កំណត់កំរិតផ្តល់ផល និងសេវាកម្មព្រៃឈើ ប្រកបដោយនិរន្តរភាព
- វាយតម្លៃព្រំប្រទល់ ធ្វើការចាត់ថ្នាក់ និងកំណត់ដែនព្រៃឈើ ដើម្បីបង្កើតផែនទីប្រើប្រាស់ដី សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ដោយសម្របសម្រួលជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន
- រៀបចំអភិវឌ្ឍ និងអនុវត្តយន្តការផ្តល់វិញ្ញាបនបត្រព្រៃឈើជាតិ សំរាប់រាល់សកម្មភាពព្រៃឈើ និងផលិតផលព្រៃឈើ
- បង្កើនការដាំដុះដើមឈើ និងស្តារព្រៃឈើឡើងវិញ នៅលើដីព្រៃរេចរិល និងផ្ទៃដីទំនេរដែលអាចដាំបាន និងថែរក្សា ការពារដើម ឈើ និងព្រៃឈើដែលបានដាំដុះកន្លងមក
- ធ្វើការសិក្សាវាយតម្លៃ កំណត់បរិមាណស្តុកកាបូនព្រៃឈើជាតិ និងរៀបចំចាត់ចែងធ្វើពាណិជ្ជកម្មកាបូនព្រៃឈើ និងសេវាព្រៃឈើកម្ពុជាដើម្បីបង្កើនចំណូលជាធនធានសំរាប់ដំណើរការ និងអភិវឌ្ឍព្រៃឈើប្រកបដោយប្រសិទ្ធភាព
- បង្កើនការអភិវឌ្ឍកិច្ចព្រមព្រៀង និងកម្មវិធីសហគមន៍ព្រៃឈើ ដោយផ្តល់នូវជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសដល់សហគមន៍មូលដ្ឋានតាមសំណើនិងការចាំបាច់
- ធានាការវាយតម្លៃ ទាន់ពេលវេលានិងពេញលេញ នូវរាល់សកម្មភាពទាក់ទង នឹងព្រៃឈើដែលមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន មុនការឯកភាពលើសកម្មភាពទាំងនេះ
- ត្រួតពិនិត្យនិងវាយតម្លៃរាល់សកម្មភាព និងការធ្វើអាជីវកម្មគ្រប់ប្រភេទ ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងព្រៃឯកជន
- អភិវឌ្ឍសមត្ថភាពស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិជ្ជា ការកែច្នៃ និង ការប្រើប្រាស់ផលព្រៃឈើប្រកបដោយប្រសិទ្ធភាពខ្ពស់
- ធ្វើការត្រួតពិនិត្យ តាមដានលើរាល់សកម្មភាពប្រមូលផល កែច្នៃ ប្រើប្រាស់ ធ្វើសន្និធិ ដឹកជញ្ជូន ពាណិជ្ជកម្ម

នាំចេញ នាំចូលនិងឆ្លងកាត់ផល អនុផល និងផលិតផលព្រៃឈើ ក្នុងទូទាំងផ្ទៃប្រទេស

- ចាត់វិធានការសមស្រប ដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់ការបំផ្លិចបំផ្លាញធនធានព្រៃឈើ ភ្លើងឆេះព្រៃ និងការកាប់ ការ ដុត ឈូសឆាយព្រៃឈើ និងដីព្រៃឈើ ដោយធានាការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់
- បង្កើនការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ តាមរយៈកម្មវិធីដែលបង្ហាញពីសារៈសំខាន់ ក្នុងការគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍ធនធានព្រៃឈើ ការចាត់វិធានការស្តារប្រព័ន្ធបរិស្ថានធម្មជាតិ និងការថែរក្សាព្រៃឈើជាតិឱ្យមានការអភិវឌ្ឍដោយចីរភាព
- បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីរួមចំណែក ពង្រឹងសមត្ថភាពគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍធនធានព្រៃឈើ សត្វព្រៃ និងជីវចំរុះប្រកបដោយចីរភាព និងប្រសិទ្ធភាពខ្ពស់
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

រដ្ឋបាលព្រៃឈើ ត្រូវដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអនុប្រធានមានឋានៈស្មើអគ្គនាយករងមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៥.-** រដ្ឋបាលព្រៃឈើ មានរចនាសម្ព័ន្ធគ្រប់គ្រង ចាត់តាំងមួយឯកភាពទូទាំងប្រទេស ជាខ្សែរយៈបណ្តោយ ដែលមាននាយកដ្ឋានចំនួន ៦ និង វិទ្យាស្ថាន ១ ដូចខាងក្រោម :

- នាយកដ្ឋានរដ្ឋបាល ផែនការនិងហិរញ្ញវត្ថុ
- នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ
- នាយកដ្ឋានសត្វព្រៃ និងជីវចំរុះ
- នាយកដ្ឋានអភិវឌ្ឍចំការព្រៃឈើ និងព្រៃឯកជន
- នាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់
- នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ
- វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ-សត្វព្រៃ

អង្គការលេខរបស់រដ្ឋបាលព្រៃឈើ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ៦.-** នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ មានភារកិច្ចដូចខាងក្រោម:

- សម្របសម្រួលសកម្មភាពការងាររដ្ឋបាល របស់អង្គភាពរដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់ និងជាមួយស្ថាប័នអង្គភាពពាក់ព័ន្ធ គ្រប់គ្រងគ្រប់ការចរាចរឯកសាររដ្ឋបាល គ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិសាធារណៈ ដែលប្រើប្រាស់ក្នុងរដ្ឋបាលព្រៃឈើ
- គ្រប់គ្រងស្ថិតិមន្ត្រីរាជការ និងទទួលការងារចំនាក់ចំនងសាធារណៈ
- សម្របសម្រួល ត្រួតពិនិត្យ វាយតំលៃ លើកសំណើដាក់វិន័យ ផ្លាស់ប្តូរផ្ទេរភារកិច្ច និងតម្លើងឋានៈ បណ្តុះបណ្តាលមន្ត្រីក្នុង និងក្រៅប្រទេស
- រៀបចំពិធីផ្លូវការ កិច្ចប្រជុំ សិក្ខាសាលា សន្និសីទ បូកសរុបលទ្ធផលការងារទូទាំង រដ្ឋបាលព្រៃឈើ និងរៀបចំរបាយការណ៍តាមការចាំបាច់
- រៀបចំ និងប្រមូលផ្តុំគម្រោងផែនការសកម្មភាពវិស័យព្រៃឈើគ្រប់ផ្នែក គ្រប់កំរិត គម្រោងកម្មវិធីវិនិយោគសាធារណៈ និងតម្រង់ទិសដៅកម្មវិធីវិនិយោគវិស័យឯកជន តាមដានវាយតម្លៃ និងគ្រប់គ្រងការងារប្រតិបត្តិ នៃការអនុវត្តផែនការ

- លើកគម្រោងចំណូលចំណាយថវិកា សំរាប់ដំណើរការរដ្ឋបាលព្រៃឈើ តាមដានលើការងារ ប្រតិបត្តិ ចុះបញ្ជីគណនេយ្យ បញ្ជីសារពើភ័ណ្ឌ គ្រប់គ្រងចលនៈទ្រព្យ-អចលនៈទ្រព្យ មធ្យោបាយសម្ភារៈបរិក្ខា និងប្រេង- ឥន្ធនៈ គ្រប់គ្រង និងត្រួតពិនិត្យចំណូលចំណាយថវិកា និងកិច្ចការហិរញ្ញវត្ថុ និងបច្ចេកទេស នៃការងារប្រតិបត្តិលទ្ធកម្មសាធារណៈ
- អភិវឌ្ឍវិធីសាស្ត្រ និងបង្កើតកម្មវិធីផ្សព្វផ្សាយអប់រំ និងដំណើរការឃោសនាការ ស្តីពីការអប់រំ យល់ដឹងសាធារណៈ ដល់មជ្ឈដ្ឋានគ្រប់ស្រទាប់ក្នុងសង្គមកម្ពុជា រៀបចំចងក្រង បោះពុម្ព ចែកផ្សាយឯកសារបច្ចេកទេស ពាក់ព័ន្ធនឹងវិស័យព្រៃឈើ សត្វព្រៃ និងជីវចំរុះ និងគ្រប់គ្រងព័ត៌មានវិស័យព្រៃឈើ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធានរដ្ឋបាលព្រៃឈើប្រគល់ជូន ។

នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៧.-** នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ មានភារកិច្ចដូចខាងក្រោម:
- សិក្សាវាយតម្លៃធនធានព្រៃឈើ រៀបចំគម្រោងផែនការគ្រប់គ្រងព្រៃឈើ និង ព្រៃសហគមន៍គ្រប់កម្រិត ត្រួតពិនិត្យ វាយតម្លៃផែនការគ្រប់គ្រងព្រៃផ្តល់ផល ព្រៃការពារ និងតាមដានវាយតម្លៃការងារប្រតិបត្តិ នៃការអនុវត្តផែនការ អភិវឌ្ឍបទដ្ឋានបច្ចេកទេស ការងារគ្រប់គ្រងព្រៃបំរុងទុកអចិន្ត្រៃយ៍ និងផ្តល់ការណែនាំក្នុងការអនុវត្តបច្ចេកទេស និងរបបគ្រប់គ្រងសំរាប់ព្រៃឈើគ្រប់ប្រភេទឱ្យមាននិរន្តរភាព រួមទាំងព្រៃផ្តល់ផល ព្រៃការពារ ព្រៃអភិរក្ស និងព្រៃសហគមន៍ ។
- រៀបចំ និង ត្រួតពិនិត្យដំណើរការអនុញ្ញាតឱ្យប្រមូលផលព្រៃឈើ និង គ្រប់គ្រងការប្រើប្រាស់ និង ចុះបញ្ជីកា គ្រឿងចក្រ យានយន្ត និង រណារយន្តគ្រប់ប្រភេទ ដែលបំរើឱ្យការប្រមូលផលព្រៃឈើ គ្រប់គ្រងបញ្ជីកាផលព្រៃឈើ និង ចាត់វិធានការអន្តរាគមន៍ភ្លើងឆេះព្រៃ
- រៀបចំកំណត់បទដ្ឋានបច្ចេកទេសស្ថាបនា និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនិងសំណង់វិស្វកម្មព្រៃឈើ ក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ និងត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្ត
- រៀបចំចាត់ថ្នាក់និងវាយតម្លៃតំបន់ទីជំរាល និង អភិវឌ្ឍផែនការគ្រប់គ្រងនិងអភិរក្សទីជម្រាល ដើម្បីការពារប្រភពក្បាលទឹក និងទប់ស្កាត់ការហូរច្រោះដី រៀបចំលិខិតបទដ្ឋាននិងក្រមបច្ចេកទេស សំរាប់ការគ្រប់គ្រងទីជម្រាល
- វាយតម្លៃ កំណត់ព្រំប្រទល់ដែនសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ចុះបញ្ជីកា និងចាត់ថ្នាក់សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ស្របតាមមុខងារព្រៃឈើ និងការប្រើប្រាស់ដីព្រៃឈើ
- គ្រប់គ្រងព័ត៌មានភូមិសាស្ត្រព្រៃឈើ រៀបចំកសាងផែនទីប្រើប្រាស់ដីព្រៃឈើ និងតំបន់ទីជំរាល ផលិតផែនទីបម្រើឱ្យវិស័យព្រៃឈើ និង គ្រប់គ្រងនិងត្រួតពិនិត្យការបោះពុម្ពនិងផ្តល់សេវាកម្មផែនទីព្រៃឈើ
- គ្រប់គ្រងព័ត៌មានសហគមន៍ព្រៃឈើ ផ្តល់សេវាកម្មបច្ចេកទេស និងសម្របសម្រួលរៀបចំបង្កើត អនុវត្ត តាមដានវាយតម្លៃ គម្រោងគ្រប់គ្រងព្រៃឈើនិងសហគមន៍ព្រៃឈើ
- តាមដាន ត្រួតពិនិត្យវាយតម្លៃ និងរាយការណ៍ពីការគ្រប់គ្រងព្រៃឈើ ប្រកបដោយនិរន្តរភាព នៅថ្នាក់ជាតិ និងកម្រិតឯកត្តា គ្រប់គ្រងតាមលក្ខណៈវិនិច្ឆ័យ និងសូចនាករគ្រប់គ្រងព្រៃឈើ ស្របតាមស្តង់ដារអន្តរជាតិ
- សម្របសម្រួលកិច្ចសហប្រតិបត្តិការ និងជំនួយគាំទ្រព្រៃឈើ និងសហគមន៍ព្រៃឈើ ជាមួយបណ្តាស្ថាប័នអាជ្ញាធរពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ បំរើអោយការងារអភិវឌ្ឍវិស័យព្រៃឈើ ចូលរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់សហគមន៍មូលដ្ឋាន

- អនុវត្តការកិច្ចផ្សេងទៀត ដែលប្រធានរដ្ឋបាលព្រៃឈើប្រគល់ជូន ។

នាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋាន មួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៨.-** នាយកដ្ឋានសត្វព្រៃ និងជីវចម្រុះ មានភារកិច្ចដូចខាងក្រោម៖

- អភិវឌ្ឍគម្រោងផែនការគ្រប់គ្រង និងអភិរក្សសត្វព្រៃ ជីវចម្រុះគ្រប់ប្រភេទ រៀបចំបទដ្ឋានបច្ចេកទេស លិខិតបទដ្ឋានគ្រប់គ្រង និងអភិរក្សសត្វព្រៃ ការធ្វើអាជីវកម្ម ពាណិជ្ជកម្មសត្វព្រៃ ដឹកជញ្ជូន ការប្រមាញ់ និង តាមដានវាយតម្លៃ ការងារប្រតិបត្តិនៃការអនុវត្តផែនការ បទដ្ឋានបច្ចេកទេស
- ស្រាវជ្រាវលក្ខណៈអេកូឡូស៊ី រប៉ាយស្ថានភាពសត្វព្រៃ ទីជម្រក និងជម្ងឺសត្វព្រៃ ស្ថេរភាព និងលទ្ធភាពជីវសាស្ត្រសត្វព្រៃ លើកវិធានការ ដំណោះស្រាយជម្លោះរវាងសត្វព្រៃ និងមនុស្ស សិក្សាស្រាវជ្រាវលក្ខណៈជីវសាស្ត្រ សត្វព្រៃគ្រប់ប្រភេទ
- កំណត់តំបន់ទេសចរធម្មជាតិ តំបន់ប្រមាញ់ និងរៀបចំ ផែនការអភិវឌ្ឍ
- គ្រប់គ្រងតំបន់ព្រៃការពារ តំបន់ទេសចរណ៍ធម្មជាតិ តំបន់កីឡាប្រមាញ់ និង ធ្វើការអភិរក្សសត្វព្រៃ ជីវចម្រុះ និងទីជំរក ផ្តល់សេវាកម្មបច្ចេកទេសចិញ្ចឹម ថែរក្សាសត្វ និងសួនសត្វគ្រប់ប្រភេទ ព្យាបាលសង្គ្រោះសត្វព្រៃ ធ្វើវិបុលកម្ម និងបង្កាត់ពូជ
- បង្កើនកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរបច្ចេកទេសវិទ្យាសាស្ត្រ ជាមួយវិស័យឯកជន អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍនានា ដើម្បីដំណើរគ្រប់គ្រង អភិរក្សសត្វព្រៃនិងជីវចម្រុះឱ្យមាននិរន្តរភាព ចាត់វិធានការអនុវត្តអនុសញ្ញាពាក់ពន្ធ័ជាមួយវិស័យព្រៃឈើ ជីវចម្រុះ សត្វព្រៃ និងទីជំរក
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធានរដ្ឋបាលព្រៃឈើប្រគល់ជូន ។

នាយកដ្ឋានសត្វព្រៃ និងជីវចម្រុះ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៩.-** នាយកដ្ឋានអភិវឌ្ឍចំការ ព្រៃដាំ និងព្រៃឯកជន មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការគ្រប់គ្រងអភិវឌ្ឍចំការព្រៃដាំគ្រប់ប្រភេទ និងគ្រប់គ្រងរួមទាំងព្រៃឯកជន និងតាមដានត្រួតពិនិត្យ វាយតម្លៃក្នុងការអនុវត្តផែនការដាំដុះ
- សិក្សា កំណត់តំបន់សំរាប់ស្តារព្រៃឈើឡើងវិញ និងអភិវឌ្ឍចំការព្រៃដាំ រៀបចំកម្មវិធីជាតិ ស្តីពីការស្តារ និងដាំដុះដើមឈើ និងព្រៃឈើ
- រៀបចំលិខិតបទដ្ឋានបច្ចេកទេស និងលិខិតបទដ្ឋានសម្រាប់ដំណើរការគ្រប់គ្រង និងអភិវឌ្ឍចំការព្រៃដាំជាដៃគូ និងព្រៃឯកជន
- សិក្សាស្រាវជ្រាវ កំណត់ និងគ្រប់គ្រងតំបន់អភិរក្សហ្សែនព្រៃឈើ និងប្រភពគ្រាប់ពូជឈើ
- ធ្វើការជ្រើសរើស ផ្គត់ផ្គង់ និងចែកចាយគ្រាប់ពូជឈើ និងវាយតម្លៃ ត្រួតពិនិត្យការនាំចេញ-ចូល ពូជរុក្ខជាតិ និងគ្រាប់ពូជឈើគ្រប់ប្រភេទ សិក្សាវាយតម្លៃ និងតាមដានពីតម្រូវការគុណភាព បរិមាណ និងប្រភេទនៃគ្រាប់ពូជ និងកូនឈើ សំរាប់ការដាំដុះក្នុងទូទាំងប្រទេស
- សម្របសម្រួល គ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកទេស លើការងារដាំដុះព្រៃឈើគ្រប់ប្រភេទ ដល់ដៃគូអភិវឌ្ឍ រួមទាំងវិស័យឯកជន សង្គមស៊ីវិល សមាគម សហគមន៍ និងគ្រួសារ ជម្រុញលើកទឹកចិត្តឱ្យមានការអភិវឌ្ឍ និងអនុវត្ត ដំណើរការកសិ-រុក្ខកម្មនៅទូទាំងប្រទេស

- សិក្សា កំណត់ទីតាំងនិង រៀបចំពិធីបុណ្យរុក្ខទិវា និងបង្កើតសួនដាំឈើ សំរាប់ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ អន្តរជាតិ ដាំដើមឈើទុកជាអនុស្សាវរីយ៍ និងបង្កើតសួនអាពាហ៍ពិពាហ៍ សំរាប់ឱ្យប្រជាពលរដ្ឋទាំងពីរភេទ ដែលជាគូស្រករថ្មីធ្វើការ ដាំដុះកូនឈើនិងការការពារដើមឈើដែលបានដាំរួច
- បង្កើនកិច្ចសហប្រតិបត្តិជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍនានា ដើម្បីធាតុវិធានការ ជំរុញលើកទឹកចិត្តឱ្យមានការចូលរួមស្តារនិងដាំដុះព្រៃឈើ សំដៅប្រយុទ្ធប្រឆាំងនឹងភាពរហោស្ថាន ការឡើងកំដៅ និងការប្រែប្រួលអាកាសធាតុ របស់ភពផែនដី
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធានរដ្ឋបាលព្រៃឈើប្រគល់ជូន ។

នាយកដ្ឋានអភិវឌ្ឍចំការព្រៃដាំ និងព្រៃឯកជន ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋាន មួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ១០.-** នាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់ មានភារកិច្ចដូចខាងក្រោម:

- សិក្សាស្រាវជ្រាវ អភិវឌ្ឍ និងកសាងបទដ្ឋានច្បាប់ បទដ្ឋានបច្ចេកទេស លិខិតបទដ្ឋានក្រោមច្បាប់ និងរៀបចំយុទ្ធសាស្ត្រ និងផែនការ ពង្រឹងការអនុវត្ត ច្បាប់ គ្រប់គ្រងនិងតាមដាន វាយតម្លៃ ណែនាំការអនុវត្តផែនការ
- ផ្សព្វផ្សាយ វាយតម្លៃ ណែនាំលើការអនុវត្តច្បាប់ និងលិខិតបទដ្ឋាន តាមដាននិងរាយការណ៍ពីបទល្មើសព្រៃឈើ ការកាប់រាន លុកលុយដីព្រៃឈើ
- គ្រប់គ្រង តាមដានឯកសារសំណុំរឿងបទល្មើសព្រៃឈើ គ្រប់ប្រភេទ ពង្រឹងទំនាក់ទំនង និងសហការជាមួយស្ថាប័ន សមត្ថកិច្ចនិងអង្គការជាតិ អន្តរជាតិ ដើម្បី អភិវឌ្ឍន៍ និងអនុវត្តការងារពង្រឹងការអនុវត្តច្បាប់
- តាមដាន ស្រាវជ្រាវស៊ើបអង្កេត ដើម្បីពង្រឹងការអនុវត្ត នីតិវិធីច្បាប់ និងអន្តរាគមន៍ បង្ក្រាបបទល្មើសព្រៃឈើ-សត្វព្រៃក្នុងទូទាំងប្រទេស តាមការចាំបាច់ ។
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធានរដ្ឋបាលព្រៃឈើប្រគល់ជូន ។

នាយកដ្ឋាននីតិកម្ម និងពង្រឹងការអនុវត្តច្បាប់ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ១១.-** នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចខាងក្រោម:

- រៀបចំផែនការគ្រប់គ្រងឧស្សាហកម្មព្រៃឈើ ផែនការអភិវឌ្ឍពាណិជ្ជកម្មព្រៃឈើ និងការងារសហប្រតិបត្តិការអន្តរជាតិ និងតាមដាន វាយតម្លៃការអនុវត្ត
- សិក្សាស្រាវជ្រាវបច្ចេកវិទ្យាកែច្នៃផលព្រៃឈើ ប្រភេទឈើមានសក្តានុពលបំរើសេចក្តីត្រូវការប្រើប្រាស់ និងទីផ្សារ សិក្សាស្រាវជ្រាវតំលៃឈើលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ និងសិក្សាលើការកំណត់ កូតានាំចេញនាំចូលផលអនុផលព្រៃឈើ
- សិក្សា និងលើកផែនការយុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍឧស្សាហកម្ម ពាណិជ្ជកម្មព្រៃឈើ តាមរយៈការបង្កើនគុណភាព ផលិតផលព្រៃឈើ និងការប្រើប្រាស់ផលព្រៃឈើ
- សម្របសម្រួលបែបបទនាំចេញ នាំចូល និងឆ្លងកាត់ និង រៀបចំលិខិតអនុញ្ញាតដឹកជញ្ជូនផល និងផលិតផលព្រៃឈើ ផលិតផលព្រៃឈើកែច្នៃ និងចូលរួមត្រួតពិនិត្យ និងបិទសំណាក្លិកលើទូផ្ទុកផល និងផលិតផលព្រៃឈើសំរាប់នាំចេញ
- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍវិធីសាស្ត្រ និងយុទ្ធសាស្ត្រក្នុងការអនុវត្តកម្មវិធីផលមានកាបូនព្រៃឈើ រៀបចំនិងអនុវត្តកម្មវិធីកាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈការគ្រប់គ្រងព្រៃឈើដោយចីរភាព និងការដាំដុះព្រៃឈើ

- រៀបចំអភិវឌ្ឍ និងអនុវត្តយន្តការផ្តល់វិញ្ញាបនបត្រព្រៃឈើជាតិ សំរាប់រាល់សកម្មភាពព្រៃឈើ និងផលិតផលព្រៃឈើ
- សម្របសម្រួលនិងបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយដៃគូអភិវឌ្ឍ រួមទាំងអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក និងតាមដានការអនុវត្តអនុសញ្ញាអន្តរជាតិ កិច្ចព្រមព្រៀង អនុស្សារណៈ ដែលពាក់ពន្ធ័នឹងវិស័យព្រៃឈើ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធានរដ្ឋបាលព្រៃឈើប្រគល់ជូន ។
- នាយកដ្ឋានឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយ អនុប្រធាននាយកដ្ឋាន មួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ១២.-** វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ-សត្វព្រៃ មានភារកិច្ចដូចខាងក្រោម:

- រៀបចំអភិវឌ្ឍ និងអនុវត្តផែនការស្រាវជ្រាវគ្រប់កម្រិត និងតាមដានវាយតម្លៃការអនុវត្ត សិក្សាស្រាវជ្រាវមូលដ្ឋានព្រៃឈើ សិក្សាអំពីប្រភេទភាពសម្បូរ និងចលនាប្រែប្រួល នៃរុក្ខជាតិព្រៃ សម្រាប់ជំនៅដ្ឋានសត្វព្រៃ សិក្សាជីវសាស្ត្រ និងជីវមណ្ឌដ្ឋានសត្វព្រៃ-ជីវចម្រុះ អង្កេត និងធ្វើសារពើភ័ណ្ឌសត្វព្រៃគ្រប់ប្រភេទ និងវាយ តម្លៃជីវចម្រុះតាមតំបន់ក្នុងភូមិភាគព្រៃឈើសំខាន់ៗ
- ធ្វើការត្រួតពិនិត្យវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថានធម្មជាតិ ចំពោះគំរោងសំណើវិនិយោគ និងអភិវឌ្ឍក្នុងវិស័យព្រៃឈើ
- សិក្សាស្រាវជ្រាវពីកត្តាមជ្ឈដ្ឋានសំខាន់ៗតាមតំបន់បរិស្ថាននីមួយៗ តាមដានវាយតម្លៃបម្រែបម្រួលកត្តាមជ្ឈដ្ឋានមាន វដ្តទឹក ដី អាកាសធាតុ ដែលពាក់ព័ន្ធនឹងព្រៃឈើ ស្រាវជ្រាវកញ្ចប់វិទ្យាសាស្ត្រ ជម្រើស និងបង្កាត់ពូជរុក្ខជាតិ-សត្វព្រៃ ពិសោធន៍ស្រាវជ្រាវដើម្បីអភិវឌ្ឍបច្ចេកទេសបង្កើនគុណភាពព្រៃឈើឡើងវិញ និងរៀបចំសួនរុក្ខតាមសាស្ត្រ និងបង្កាត់ពូជរុក្ខជាតិផ្តល់សោភ័ណភាព និងលំអ
- សិក្សាស្រាវជ្រាវអត្តសញ្ញាណ និងការប្រើប្រាស់ផលអនុផលព្រៃឈើ បច្ចេកវិទ្យាកែច្នៃ និងបង្កើនគុណភាពតម្លៃ និងស្តង់ដារផលិតផលព្រៃឈើ វិភាគពីសង្គម-សេដ្ឋកិច្ចក្នុងការផ្លាស់ប្តូរមុខរបរ ដើម្បីកាត់បន្ថយសម្ពាធប៉ះពាល់ព្រៃឈើ
- បង្កើនកិច្ចសហការជាមួយដៃគូអភិវឌ្ឍ និងបណ្តាញអន្តរជាតិលើការងារស្រាវជ្រាវព្រៃឈើ សត្វព្រៃ និងជីវចំរុះ ព្រមទាំងប្រមូលព័ត៌មានចងក្រង បោះពុម្ពឯកសារវិទ្យាសាស្ត្រ ដែលជាលទ្ធផលស្រាវជ្រាវ និងផ្សព្វផ្សាយការអនុវត្ត
- សិក្សាស្រាវជ្រាវនិងបង្កើតស្ថានីយ៍ស្រាវជ្រាវព្រៃឈើ និងជីវចំរុះ នៅតាមភូមិភាគ និងប្រភេទព្រៃឈើសំខាន់ៗ
- រៀបចំអភិវឌ្ឍកម្មវិធី និងផែនការពង្រឹងសមត្ថភាព និងបណ្តុះបណ្តាលធនធានមនុស្ស សំរាប់រដ្ឋបាលព្រៃឈើ និងការអភិវឌ្ឍវិស័យព្រៃឈើ
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធានរដ្ឋបាលព្រៃឈើប្រគល់ជូន

វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ-សត្វព្រៃ ដឹកនាំដោយប្រធានវិទ្យាស្ថានមួយរូប មានឋានៈស្មើនឹងប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានវិទ្យាស្ថានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

ផ្នែកទី ៣

**រដ្ឋបាលជលផល**

**មាត្រា ១៣.-** រដ្ឋបាលជលផល មានបេសកកម្មដូចតទៅ :

- អភិវឌ្ឍធនធានជលផល និងជីវចំរុះ ប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកធានាសន្តិសុខស្បៀង លើកកម្ពស់ កំរិតជីវភាពរស់នៅរបស់ប្រជាជន ការរីកចំរើននៃសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍប្រទេសជាតិ
- ធានាការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផល ប្រកបដោយនិរន្តរភាព
- អភិវឌ្ឍវារីវប្បកម្មដើម្បីរួមចំណែកធានាសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ
- ធានាគុណភាព និងសុវត្ថិភាពផល និងផលិតផលជលផល
- អភិវឌ្ឍ និងគ្រប់គ្រងខ្សែសង្វាក់ផលិតកម្មផល និងផលិតផលជលផល

**មាត្រា ១៤.-** រដ្ឋបាលជលផល មានតួនាទីភារកិច្ច ធ្វើជាសេនាធិការឱ្យក្រសួង លើការងារ ដូចតទៅ៖-

- គ្រប់គ្រងធនធានជលផល ប្រកបដោយប្រសិទ្ធភាព និរន្តរភាព សមធម៌ មានការចូលរួម និងភាពទទួលខុសត្រូវ
- សិក្សាស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសជលផល ប្រមូលទិន្នន័យទាក់ទងនឹងកត្តាសេដ្ឋកិច្ចសង្គម និង បរិស្ថាន ដើម្បីអភិវឌ្ឍ អភិរក្ស និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព
- អភិវឌ្ឍធនធានមនុស្ស និងជំរុញការគ្រប់គ្រង តាមគ្រប់លំដាប់ថ្នាក់ ឱ្យមានប្រសិទ្ធភាពខ្ពស់
- ចូលរួមអនុវត្តគោលនយោបាយវិស័យជលផលជាតិ និងរៀបចំផែនការអនុវត្ត នៅតាមថ្នាក់នីមួយៗ
- រៀបចំតាក់តែងលិខិតបទដ្ឋាន ច្បាប់នានា សំដៅគ្រប់គ្រងវិស័យជលផល ឱ្យមានប្រសិទ្ធភាព
- សិក្សាវាយតំលៃ ធ្វើចំណាត់ថ្នាក់ កំណត់ព្រំប្រទល់ដែននេសាទ បង្កើតដែនទីដែននេសាទ
- ថែរក្សាការពារព្រៃលិចទឹក និងព្រៃកោងកាង និងរៀបចំដាំឡើងវិញ
- បង្កើនការអភិវឌ្ឍវារីវប្បកម្មទឹកសាប សមុទ្រ តាមគ្រប់រូបភាព
- ពង្រឹងការអភិវឌ្ឍសហគមន៍នេសាទ ដោយផ្សព្វផ្សាយបច្ចេកទេសសមស្រប ក្នុងសហគមន៍
- ចាត់វិធានការសមស្រប ដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសបំផ្លិចបំផ្លាញធនធានជលផល
- បង្កើនការអប់រំជាសាធារណៈ តាមរយៈកម្មវិធីបង្ហាញ ពីសារៈសំខាន់នៃការគ្រប់គ្រង ការពារ ថែរក្សាធនធាន ជលផល និងជីវចំរុះ
- ធានាការវាយតំលៃទាន់ពេលវេលា រាល់សកម្មភាពដែលមានផលប៉ះពាល់លើវិស័យសេដ្ឋកិច្ចសង្គម និង បរិស្ថាន មុនការឯកភាពលើសកម្មភាពទាំងនោះ
- ធ្វើបញ្ជីសារពើភ័ណ្ឌប្រភេទឧបករណ៍សំភារៈ និងមធ្យោបាយនេសាទ កំណត់អត្តសញ្ញាណប្រភេទ ធនធានជលផល និងជីវចំរុះ
- ចាត់វិធានការជាក់ស្តែង ក្នុងការកែលំអប្រព័ន្ធអេកូឡូស៊ីជលផល
- រៀបចំឯកសារមូលដ្ឋាន សំរាប់ការដេញថ្លៃឡូតិ៍នេសាទ ក្នុងទូទាំងប្រទេស និងរៀបចំឯកសារមូលដ្ឋាន កំណត់ថ្លៃ ឈ្នួលនេសាទ
- បង្កើនកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ថ្នាក់អន្តរជាតិ និងដៃគូអភិវឌ្ឍនានា សំដៅពង្រឹង និងពង្រីកសមត្ថភាព ជំនាញ ដើម្បីកិច្ចការពារ និងអភិវឌ្ឍធនធានជលផល
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

រដ្ឋបាលជលផល ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអនុប្រធានមានឋានៈស្មើអគ្គនាយករង មួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ១៥.-** រដ្ឋបាលជលផល មានរចនាសម្ព័ន្ធគ្រប់គ្រង ចាត់តាំងមួយឯកភាពទូទាំងប្រទេស ជាខ្សែរយៈបណ្តោយ ដែលមាននាយកដ្ឋានចំនួន ៧ និងវិទ្យាស្ថាន ២ ដូចខាងក្រោម :

- នាយកដ្ឋានកិច្ចការរដ្ឋបាល និងទីតិកម្ម
- នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ
- នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម
- នាយកដ្ឋានកិច្ចការជលផល
- នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ
- នាយកដ្ឋានបច្ចេកវិទ្យាកែច្នៃនិងគុណភាព
- នាយកដ្ឋានអភិរក្សជលផល
- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប
- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ

អង្គការលេខ របស់រដ្ឋបាលជលផល ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា ១៦.-** នាយកដ្ឋានកិច្ចការរដ្ឋបាល និងទីតិកម្ម មានភារកិច្ច ដូចខាងក្រោម :

- សម្របសម្រួល ទំនាក់ទំនង និងពិធីការជាមួយបណ្តាស្ថាប័ន និងអង្គការនានា និងគ្រប់គ្រងសណ្តាប់ធ្នាប់ សន្តិសុខ និងទំនាក់ទំនងផ្ទៃក្នុងរដ្ឋបាលជលផល
- ចូលរួមត្រួតពិនិត្យ វាយតម្លៃលទ្ធផលការងារ និងលើកសំណើតែងតាំង វាយតម្លៃ លើកសរសើរ រំសាយ-ឋានៈ តួនាទី ឬកែសម្រួលរចនាសម្ព័ន្ធ តាមស្ថានភាពជាក់ស្តែង
- រៀបចំការងារបុគ្គលិក ប្រាក់កម្រៃ និងរបបឧបត្ថម្ភមន្ត្រីជលផល និងបែងចែក ផ្គត់ផ្គង់ គ្រប់គ្រង និងជួសជុលអាគារ យានយន្ត និងសម្ភារៈប្រើប្រាស់របស់រដ្ឋបាលជលផល
- គ្រប់គ្រងបណ្ណាល័យ និងប្រព័ន្ធព័ត៌មានវិទ្យាជលផល
- រៀបចំផែនការអភិវឌ្ឍធនធានមនុស្ស និងគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការ និងជម្រុញលើកទឹកចិត្តឱ្យមានសមភាព និងសមធម៌យេនឌ័រ
- ចូលរួមរៀបចំ និងសម្របសម្រួលការបណ្តុះបណ្តាលពង្រឹងសមត្ថភាពជំនាញនានា និងបំពាក់បំប៉ននីតិវិធីទប់ស្កាត់បទល្មើស ជំនាញយុត្តិធម៌ និងក្រមសីលធម៌ដល់មន្ត្រីនគរបាលយុត្តិធម៌ជលផល
- បណ្តុះបណ្តាល និងផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានគតិយុត្តនានា
- រៀបចំ កសាង ពិនិត្យ និងកែសម្រួលសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យជលផល
- រៀបចំសំណុំរឿង ដោះស្រាយបទល្មើសជលផលតាមនីតិវិធី តាមដាន និងជម្រុញការអនុវត្តសេចក្តីសម្រេចអំពីអំពើល្មើសជលផល និងត្រួតពិនិត្យបញ្ជីសំណុំរឿងបទល្មើសជលផល នៅគ្រប់លំដាប់ថ្នាក់ របស់រដ្ឋបាលជលផល
- ធ្វើអន្តរាគមន៍ និងចុះជួយទប់ស្កាត់បទល្មើសជលផលក្នុង ទូទាំងប្រទេស
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ឱ្យ ។

នាយកដ្ឋានកិច្ចការរដ្ឋបាល និងទីតិកម្ម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ១៧.-** នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ច ដូចខាងក្រោម :

- រៀបចំ និងសម្របសម្រួលការកសាងគោលនយោបាយវិស័យជលផល និងកសាងគម្រោងផែនការសកម្មភាព វិស័យជលផលរយៈពេលខ្លី មធ្យម និង វែង
- វិភាគ ផ្តល់យោបល់ និងរៀបចំគម្រោងវិនិយោគសាធារណៈ និងវិនិយោគឯកជនក្នុងវិស័យជលផល
- គ្រប់គ្រងស្ថិតិជលផល ឧបករណ៍សម្ភារៈជលផល និង តាមដានទីផ្សារជលផល
- ប្រមូលសរុបរបាយការណ៍ សភាពការណ៍វិស័យជលផល និងរៀបចំរបាយការណ៍តាមដានវាយតម្លៃសកម្មភាពអនុវត្ត ប្រចាំត្រីមាស និងប្រចាំឆ្នាំ
- គ្រប់គ្រងការបង្កើតទីតាំងលក់ សន្និធិ (ស្តុក) និងដឹកជញ្ជូនផល ផលិតផលជលផល
- រៀបចំនិងសម្របសម្រួលការកសាងផែនការហិរញ្ញវត្ថុលើគ្រប់ផ្នែក និងពិនិត្យកិច្ចសន្យាពាក់ព័ន្ធវិស័យជលផល
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- ប្រមូលថ្លៃឈ្នួលនេសាទ ប្រាក់ពិន័យ ប្រាក់លក់ឧបករណ៍ និង សម្ភារៈនេសាទរឹបអូស និងបំណុលផ្សេងៗ
- គ្រប់គ្រងការងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនង រៀបចំគម្រោងកិច្ចសហការជាមួយស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអង្គការនានា
- តាមដាន ជម្រុញ និងវាយតម្លៃលើការអនុវត្តកំណត់ហេតុ អនុស្សរណៈ ពិធីសារ អនុសញ្ញា និងកិច្ចព្រមព្រៀងនានា ពាក់ព័ន្ធនឹងវិស័យជលផល
- គ្រប់គ្រង ពិនិត្យ និងសម្របសម្រួលគ្រប់សកម្មភាពការងារ ពាក់ព័ន្ធនឹងការរៀបចំលើកសំណើគម្រោង របស់គ្រប់អង្គភាពជលផល និងជួយស្វែងរកដៃគូម្ចាស់ជំនួយអន្តរជាតិជាទ្វេភាគី ឬពហុភាគី ដើម្បីគាំទ្រគម្រោង
- តាមដាន និងវាយតម្លៃផលប៉ះពាល់គោលនយោបាយវិស័យជលផល និងការអនុវត្តផែនការសកម្មភាព នៃវិស័យជលផល
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ឱ្យ ។

នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ១៨.-** នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម មានភារកិច្ច ដូចខាងក្រោម :

- រៀបចំគោលនយោបាយ ផែនការមេ សម្រាប់អភិវឌ្ឍន៍វារីវប្បកម្ម
- រៀបចំលិខិតបទដ្ឋានសម្រាប់គ្រប់គ្រង និងអភិវឌ្ឍន៍វារីវប្បកម្ម
- ជំរុញ និងអភិវឌ្ឍកម្មវិធីសិក្សា ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រវារីវប្បកម្ម រួមទាំងប្រភេទជិតផុតពូជ
- គ្រប់គ្រងការនាំចូល នាំចេញវារិជាត ឧបករណ៍ ថ្នាំពុល សារធាតុពុល សារធាតុគីមី សារធាតុរ៉ែដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវារីវប្បកម្ម
- ជំរុញការងារផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម តាមគ្រប់រូបភាព កសាង និងបណ្តុះបណ្តាលធនធានមនុស្ស ទាំងក្នុង និងក្រៅស្ថាប័ន
- ជំរុញការអភិវឌ្ឍប្រពន្ធ័វារីវប្បកម្ម ទាំងស្ថាប័នជាតិ និងឯកជន ដើម្បីធ្វើឱ្យប្រសើរឡើងនូវផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន ហើយឆ្លើយតបបានទៅនឹងគោលបំណងអភិវឌ្ឍន៍ជាតិ តម្រូវការទីផ្សារ និងកាតព្វកិច្ចអន្តរជាតិ
- ពង្រឹង និងពង្រីកការអភិវឌ្ឍន៍ស្រះចម្រុះគ្រួសារ តាមជនបទ និងតំបន់ឆ្ងាយពីដែននេសាទ

- គ្រប់គ្រងការធ្វើវារីវប្បកម្មគ្រប់ប្រភេទ និងការបញ្ចេញកាកសំណល់ របស់កសិដ្ឋានវារីវប្បកម្ម
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានអប់រំ ស្រាវជ្រាវ ដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ និងវិស័យឯកជន ដើម្បីជំរុញការអភិវឌ្ឍន៍វារីវប្បកម្ម និងគ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវារីវប្បកម្ម
- ជំរុញ និងលើកទឹកចិត្តដល់ការវិនិយោគ សហគ្រាសធុនមធ្យម និងឧស្សាហកម្មលើវិស័យវារីវប្បកម្ម
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ១៩.-** នាយកដ្ឋានកិច្ចការជលផល មានភារកិច្ច ដូចខាងក្រោម ៖

- សិក្សាកសាងផែនទី និងកំណត់ព្រំប្រទល់ដែននេសាទ
- រៀបចំស្ដារ និងកែលំអដែននេសាទ
- រៀបចំឯកសារកំណត់តំបន់ ដែលត្រូវអនុញ្ញាតឱ្យដាំដុះវារីរុក្ខជាតិនានា ក្នុងដែននេសាទ
- សិក្សាស្រាវជ្រាវតំបន់ដែលអនុញ្ញាតឱ្យធ្វើសំណង់ និងការងារអភិវឌ្ឍន៍នានាក្នុងដែននេសាទ
- រៀបចំសៀវភៅបន្ទុកឡូត៍នេសាទ សៀវភៅនាវានេសាទ និងរៀបចំសំណុំឯកសារវិនិយោគ ដេញថ្លៃ ឬជួលឡូត៍នេសាទ និងកំណត់ថ្លៃឈ្នួលឡូត៍នេសាទ
- ពិនិត្យ និងសហការដោះស្រាយ បញ្ហាដែលពាក់ព័ន្ធនឹងការធ្វើអាជីវកម្មនេសាទ
- តាមដាន និងវាយតម្លៃសភាពការណ៍អាជីវកម្មនេសាទ និងដែននេសាទ
- គ្រប់គ្រង ចាត់ចែងការអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទ និងប្រើប្រាស់ទូក កាណូត នាវានេសាទ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ឱ្យ ។

នាយកដ្ឋានកិច្ចការជលផល ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ២០.-** នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ មានភារកិច្ច ដូចខាងក្រោម ៖

- ជម្រុញ និងសម្របសម្រួលរៀបចំបង្កើត និងអភិវឌ្ឍន៍សហគមន៍នេសាទ
- រៀបចំប្រព័ន្ធការងារស្រាវជ្រាវផ្នែកសេដ្ឋកិច្ចសង្គម និងអភិវឌ្ឍន៍សហគមន៍នេសាទ
- កំណត់ព្រំប្រទល់សហគមន៍នេសាទ និងរៀបចំការអភិរក្សធនធានជលផល ក្នុងកន្លែងនេសាទសហគមន៍
- សហការកំណត់កន្លែងនេសាទសហគមន៍ និងដោះស្រាយទំនាស់ ដែលកើតក្នុងសហគមន៍នេសាទ
- សហការ និងទំនាក់ទំនងជាមួយបណ្ដាស្ថាប័ន អង្គការ និងសហគមន៍ពាក់ព័ន្ធ ដើម្បីជម្រុញ និងលើកកំពស់ការពង្រឹងសមត្ថភាព និងការអភិវឌ្ឍសហគមន៍នេសាទ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត របស់សហគមន៍នេសាទ
- សម្របសម្រួលការរៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ផែនការគ្រប់គ្រងកន្លែងនេសាទ និងការចុះបញ្ជីសហគមន៍នេសាទ
- ជម្រុញការអនុវត្តសកម្មភាព មុខរបរចិញ្ចឹមជីវិតនៅក្នុងសហគមន៍នេសាទ ដែលមិនជះឥទ្ធិពលអវិជ្ជមាន ដល់ធនធានជលផល
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ឱ្យ ។

នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**មាត្រា ២១.-** នាយកដ្ឋានបច្ចេកវិទ្យាកែច្នៃ និងគុណភាព មានភារកិច្ច ដូចខាងក្រោម :

- សិក្សាស្រាវជ្រាវអំពីទំនាក់ទំនង និងខ្សែសង្វាក់ផលិតកម្មផល ផលិតផលជលផល
- សិក្សាស្រាវជ្រាវកំណត់ស្តង់ដារនៃគុណភាព និងសុវត្ថិភាពនៃផល ផលិតផលជលផល
- សិក្សាស្រាវជ្រាវតួនាទីនៃផល ផលិតផលជលផល ក្នុងសន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- រៀបចំលិខិតបទដ្ឋានបច្ចេកទេស ដែលទាក់ទងទៅនឹងគុណភាព សុវត្ថិភាព ការថែរក្សាការពារគុណភាពផល ផលិតផលជលផល និងស្ថានភាពសុខភាពវារីជាតិ
- ដោះស្រាយរាល់បញ្ហាទាក់ទងទៅនឹងអនាម័យ គុណភាព សុវត្ថិភាពផល ផលិតផលជលផល នៅក្នុងផ្នែកផលិតកម្ម កែច្នៃ និងអាជីវកម្ម
- តាមដាន ត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផល ផលិតផលជលផល និងចត្តាឡីស័ក
- វិភាគ វាយតម្លៃ និងបញ្ជាក់គុណភាព សុវត្ថិភាពជលផលផលិតផលជលផល
- សិក្សាស្រាវជ្រាវទៅលើសេដ្ឋកិច្ចសង្គម និងទីផ្សារនៅក្នុងផលិតកម្មកែច្នៃ និងអាជីវកម្ម
- សិក្សាស្រាវជ្រាវអំពីបច្ចេកទេសវេចខ្ចប់ និងថែរក្សា និងរយៈពេលប្រើប្រាស់ផល ផលិតផលជលផល
- បង្កើត រក្សាទុកមូលដ្ឋានទិន្នន័យបច្ចេកទេសវិទ្យាសាស្ត្រ និងផ្សព្វផ្សាយព័ត៌មាន អំពីបច្ចេកទេសវិទ្យាកែច្នៃផលជលផល ព័ត៌មានទីផ្សារ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- បណ្តុះបណ្តាលពីបច្ចេកវិទ្យាកែច្នៃផលជលផល ព័ត៌មានទីផ្សារ សន្តិសុខស្បៀង និងអាហារូបត្ថម្ភ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

នាយកដ្ឋានបច្ចេកវិទ្យាកែច្នៃ និងគុណភាព ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋាន មួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ២២.-** នាយកដ្ឋានអភិរក្សជលផល មានភារកិច្ច ដូចខាងក្រោម :

- ចងក្រងលិខិតបទដ្ឋានសម្រាប់ការបង្កើតកន្លែងអភិរក្ស និងគ្រប់គ្រងប្រភេទវារីជាតិដែលជិតផុតពូជ
- សិក្សា និងកំណត់កន្លែងអភិរក្សជលផលទឹកសាប និងសមុទ្រ
- រៀបចំកន្លែងការពារ អភិរក្ស និងដែនជម្រកសុវត្ថិភាពធនធានជលផល
- សិក្សា និងកំណត់ប្រភេទវារីជាតិដែលជិតផុតពូជ
- រៀបចំបង្កើតកន្លែងការពារ និងអភិរក្សវារីជាតិដែលជិតផុតពូជ
- រៀបចំបង្ការភ្លើងឆេះព្រៃ កែលំអ និងដាំព្រៃលិចទឹក និងព្រៃកោងកាងឡើងវិញ
- ស្រាវជ្រាវ និងរៀបចំប្រមូលចងក្រង ថែរក្សា និងអភិរក្សគំរូសំណាកវារីជាតិ និងឧបករណ៍នេសាទ
- រៀបចំសារមន្ទីរថែរក្សាសំណាក ផលិតផលជលផល និងឧបករណ៍នេសាទ
- រៀបចំ រចនា បង្កើត និងគ្រប់គ្រងជលវប្បដ្ឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ឱ្យ ។

នាយកដ្ឋានអភិរក្សជលផល ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ២៣.-** វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប មានភារកិច្ច ដូចខាងក្រោម :

- សិក្សាស្រាវជ្រាវ អង្កេត តាមដានស្ថានភាពធម្មជាតិ ជីវចំរុះ បណ្តាធនធានជលផលទឹកសាប និងធ្វើអត្តសញ្ញាណកម្ម វារីជាតទឹកសាប ដែលមានការពាក់ព័ន្ធទៅនឹងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍវិស័យជលផល
- រៀបចំ និងអនុវត្តកម្មវិធីស្រាវជ្រាវលើប្រធានបទ ដែលពាក់ព័ន្ធទៅនឹងអេកូឡូស៊ី ជីវសាស្ត្រ បច្ចេកទេស និងសេដ្ឋកិច្ចសង្គមនៃជលផលទឹកសាប
- សិក្សាស្រាវជ្រាវ ចាត់ថ្នាក់ និងរៀបចំបទដ្ឋានពាក់ព័ន្ធ ដើម្បីកំណត់ប្រសិទ្ធភាព ផលប្រយោជន៍ ទំនាក់ទំនង និងផលប៉ះពាល់ រវាងព្រៃលិចទឹកជាមួយប្រព័ន្ធអេកូឡូស៊ី
- សិក្សាស្រាវជ្រាវ និងកំណត់ប្រសិទ្ធភាពនៃឧបករណ៍នេសាទទឹកសាប
- សិក្សាស្រាវជ្រាវ អំពីការជះឥទ្ធិពល នៃរាល់សកម្មភាពគ្រប់គ្រងទឹក លើធនធានវារីជាតិ
- សិក្សាស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសជលផល តាមរយៈការធ្វើអាជីវកម្មនេសាទ
- សិក្សាស្រាវជ្រាវ វិភាគ ការពារ ព្យាបាល និងតាមដានសុខភាពវារីជាត និងប្រព័ន្ធអេកូឡូស៊ីជលផល
- សិក្សាស្រាវជ្រាវ ជ្រើសរើស និងថែបំប៉នត្រីមេពូជ សំរាប់បំរើការងារបង្កាត់ភ្ញាស់ និងផលិតកូនត្រី
- សិក្សាស្រាវជ្រាវការផលិតពូជ បង្កាត់ពូជ និងសេនេទិក
- សិក្សាស្រាវជ្រាវការប្រើប្រាស់ថ្នាំ និងអរម៉ូន សំរាប់បំរើការងារបង្កាត់ភ្ញាស់ត្រី
- សិក្សាស្រាវជ្រាវការថែបំប៉នកូនត្រីខ្សៀ-កូនត្រីពូជ
- សិក្សាស្រាវជ្រាវការធ្វើវារីវប្បកម្ម ដែលមានតំលៃសេដ្ឋកិច្ច នៅក្នុងស្រះ បែ និងស្រែ
- សិក្សាស្រាវជ្រាវការចិញ្ចឹមត្រីស៊ីសាច់ ដែលមានឥទ្ធិពលប៉ះពាល់ដល់ធនធានធម្មជាតិ
- សិក្សាស្រាវជ្រាវការផលិតចំណីធម្មជាតិ និងចំណីសិប្បនិម្មិត ដើម្បីបំរើឱ្យការងារវារីវប្បកម្ម
- សិក្សាស្រាវជ្រាវវិភាគគុណភាពទឹក ចំណី ជំងឺត្រី និងព្យាបាលជំងឺត្រី
- បណ្តុះបណ្តាល និងបំពាក់បំប៉នបច្ចេកទេសវិទ្យាសាស្ត្រផលិតកូនត្រីពូជ និងត្រីសាច់
- បង្កើតមូលដ្ឋានទិន្នន័យព័ត៌មាន ចងក្រង និងផ្សព្វផ្សាយព័ត៌មានបច្ចេកទេសវិទ្យាសាស្ត្រ និងឯកសារបច្ចេក-ទេសផ្នែកជលផល និងវារីវប្បកម្មទឹកសាប
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ឱ្យ ។

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប ដឹកនាំដោយនាយកវិទ្យាស្ថានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយនាយករងមួយចំនួន ជាជំនួយការ តាមការចាំបាច់។

**មាត្រា ២៤.-** វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ មានភារកិច្ច ដូចខាងក្រោម :

- ស្រាវជ្រាវ អង្កេត តាមដានស្ថានភាពធម្មជាតិ និងធនធានជលផលសមុទ្រដទៃទៀត ជីវចំរុះ អេកូឡូស៊ី សាគរសាស្ត្រ និងបច្ចេកទេស និងសេដ្ឋកិច្ចសង្គម នៃការនេសាទសមុទ្រ
- សិក្សាស្រាវជ្រាវ និងកំណត់ប្រសិទ្ធភាព នៃឧបករណ៍នេសាទសមុទ្រ
- ស្រាវជ្រាវអំពីការជះឥទ្ធិពលលើធនធានវារីជាត ដែលបណ្តាលមកពីសកម្មភាពនានា
- ស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេសវារីវប្បកម្មសមុទ្រ និងចងក្រង ផ្សព្វផ្សាយឯកសារវិទ្យាសាស្ត្របច្ចេកទេស វារីវប្បកម្មសមុទ្រ
- ស្រាវជ្រាវអំពីទំនាក់ទំនង និងផលប៉ះពាល់ រវាងការធ្វើនេសាទសមុទ្រ និងវារីវប្បកម្ម
- បង្កើត រក្សាទុក ផ្លាស់ប្តូរ និងផ្សព្វផ្សាយនូវរាល់មូលដ្ឋានទិន្នន័យ និងព័ត៌មានវិទ្យាសាស្ត្រជាមួយគ្រប់ស្ថាប័ន

ពាក់ព័ន្ធ និងអ្នកប្រើប្រាស់ ដើម្បីអភិរក្ស គ្រប់គ្រង និងធានាដល់ការប្រើប្រាស់

- សិក្សាស្រាវជ្រាវ បង្កើនសមត្ថភាពមន្ទីរពិសោធន៍ខាងផ្នែកចំណី ជំងឺវារីសត្វ វារីរុក្ខជាតិសមុទ្រ និងសេនេទិក
- សិក្សាស្រាវជ្រាវ ផលិតប្រភេទវារីសត្វ វារីរុក្ខជាតិសមុទ្រគ្រប់ប្រភេទ ដែលជិតផុតពូជ
- បំពាក់បំប៉នសមត្ថភាពជំនាញបច្ចេកទេសវិទ្យាសាស្ត្រ និងការគ្រប់គ្រងធនធានជលផលសមុទ្រ
- ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័ននានា ក្នុងកិច្ចសហការ ស្រាវជ្រាវជលផលសមុទ្រ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ ដឹកនាំដោយនាយកវិទ្យាស្ថានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយនាយករងមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

## ផ្នែកទី ៤

## អគ្គនាយកដ្ឋានកសិកម្ម

**មាត្រា ២៥.-** អគ្គនាយកដ្ឋានកសិកម្ម មានបេសកកម្មដូចតទៅ:

- ធានាបាននូវសន្តិសុខស្បៀង សំរាប់ប្រជាពលរដ្ឋ
- គ្រប់គ្រង និងត្រួតពិនិត្យគុណភាព និងសុវត្ថិភាពកសិផល
- ជំរុញកំណើនផលិតភាពកសិកម្មតាមរយៈពិពិធកម្មកសិកម្ម
- រួមចំណែកកាត់បន្ថយភាពក្រីក្រ តាមរយៈបង្កើនចំណូលដល់កសិករ ដោយតម្លៃបន្ថែមលើកសិផល
- ធានាទីផ្សារកសិផល ។

**មាត្រា ២៦.-** អគ្គនាយកដ្ឋានកសិកម្ម មានភារកិច្ច ធ្វើជាសេនាធិការអោយក្រសួង លើការងារ ដូចតទៅ :

- រៀបចំរសំណើគោលនយោបាយ ផែនការ កម្មវិធី គំរោង និងវិធានការអភិវឌ្ឍផលិតកម្មដំណាំ ស្របតាមលក្ខខ័ណ្ឌអេកូឡូស៊ីបរិស្ថាន សក្តានុពលធនធានដី ស្ថានភាពប្រែប្រួលនៃអាកាសធាតុ តំរូវការ ទីផ្សារ និងនិរន្តរភាពនៃធនធានធម្មជាតិ និងបរិស្ថាន
- ពិសោធន៍ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រ ដែលទាក់ទងនឹងកិច្ចអភិវឌ្ឍន៍ផលិតកម្មដំណាំ សេដ្ឋកិច្ចកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង លើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន និងជំរុញបង្កើនការនាំចេញកសិផល
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយ ប្រកបដោយប្រសិទ្ធភាព នូវសេវាកម្មណែនាំបច្ចេកទេសផលិតកម្មដំណាំ និងសេវាគាំទ្រ ដល់កសិករ និងវិស័យឯកជន ដើម្បីបង្កើនផលិតភាពកសិកម្ម និងផលិតកម្មកសិកម្ម
- ចងក្រងរៀបចំជាអង្គការកសិករ អង្គការផលិតករកសិកម្ម និងសំរបសំរួលរវាងប្រតិបត្តិករសាធារណៈ ឯកជន និងកសិករ ផលិតករកសិកម្ម ដើម្បីលើកកំពស់ប្រសិទ្ធភាពការងារអប់រំផ្សព្វផ្សាយ ណែនាំវិធានការអភិវឌ្ឍផលិតកម្មដំណាំ ផ្តល់សេវាគាំទ្រ សំរបសំរួលទីផ្សារកសិផល បែងចែកផលចំណេញដល់ប្រកសិករ
- ជំរុញបង្កើនផលិតភាពកសិកម្ម និងប្រាក់ចំណូលពីផលិតកម្មកសិកម្ម ដោយប្រើប្រាស់ពូជដំណាំសមស្រប ការប្រើប្រាស់ធនធានដី ការស្រោចស្រព ការអនុវត្តវិធីសាស្ត្រដាំដុះសមស្របតាមអេកូឡូស៊ីបរិស្ថាន ការលើកប្រសិទ្ធភាពអនាម័យ និងការការពារដំណាំ និង ការប្រើប្រាស់គ្រឿងយន្តកសិកម្ម ដែលសមស្របតាម លក្ខណភូមិសាស្ត្រសេដ្ឋកិច្ចសង្គម
- ផ្តល់សេវាវិភាគស្រាវជ្រាវ វាយតំលៃគុណភាពដីកសិកម្ម ស្ថានភាពសុខភាពដំណាំ ពូជគ្រប់ប្រភេទនៃដំណាំ

អត្តសញ្ញាណកម្មសមាសភាពថ្លៃ សារធាតុគីមីកសិកម្ម និងភ្នាក់ងារជីវសាស្ត្រ ដែលប្រើប្រាស់ក្នុងផលិតកម្មដំណាំ

- រៀបចំលិខិតបទដ្ឋាន និងច្បាប់ ក្នុងការគ្រប់គ្រងការប្រើប្រាស់សារធាតុគីមីកសិកម្ម ភ្នាក់ងារជីវសាស្ត្រ ពូជដំណាំ និងសម្ភារៈផ្សេងទៀត ដែលប្រើប្រាស់ក្នុងផលិតកម្មដំណាំ អនុវត្តវិធានអនាម័យ និងភូតគាមអនាម័យគ្រប់គ្រងគុណភាពផលិតផលដំណាំ ដើម្បីធានាបង្កើនប្រសិទ្ធភាពនិងនិរន្តរភាព នៃផលិតភាព ផលិតកម្មដំណាំ
- ជំរុញកិច្ចសហការ និងអនុវត្តស្តង់ដារ គោលការណ៍ណែនាំ ពិធីសារ អនុស្សារណៈ កិច្ចព្រមព្រៀង និងបណ្តាលិខិតបទដ្ឋានក្នុងតំបន់ និងក្នុងអន្តរជាតិ
- តាមដានសុខភាពដំណាំ និងព្យាករណ៍សត្វានុពលមានិភ័យនៃការរាតត្បាតរបស់សមាសភាពចង្រៃ លើដំណាំ ដោយធានាវិធានការកំចាត់ និងកាត់បន្ថយ ផលប៉ះពាល់
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

អគ្គនាយកដ្ឋានកសិកម្ម ដឹកនាំដោយ អគ្គនាយកមួយរូប និងអគ្គនាយករងមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា ២៧.-** រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានកសិកម្ម មាននាយកដ្ឋានចំនួន ៩ និងមន្ទីរពិសោធន៍ជាតិកសិកម្ម ចំនួន ១ ដូចខាងក្រោម:

- នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ
- នាយកដ្ឋានដំណាំស្រូវ
- នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ
- នាយកដ្ឋានដំណាំឧស្សាហកម្ម
- នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ
- នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម
- នាយកដ្ឋានគ្រឿងយន្តកសិកម្ម
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
- មន្ទីរពិសោធន៍ជាតិកសិកម្ម

អង្គការលេខ របស់អគ្គនាយកដ្ឋានកសិកម្ម ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២៨.-** នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចខាងក្រោម:

- រៀបចំ និងចាត់ចែងការងារគ្រប់គ្រងមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានកសិកម្ម ដែលរាប់បញ្ចូលទាំងការគ្រប់គ្រងស្ថិតិមន្ត្រី ពិធីការ ការផ្ទេរភារកិច្ចនិងឋានៈ ការលើកសរសើរ ឬដាក់ពិន័យ និងរៀបចំគោលនយោបាយ ពាក់ព័ន្ធនឹង ក្របខ័ណ្ឌបៀវត្សរ៍ ប្រាក់កំរៃ របបឧបត្ថម្ភផ្សេងៗ
- រៀបចំផែនការបណ្តុះបណ្តាល និងចាត់ចែងការងារបណ្តុះបណ្តាល មន្ត្រីរាជការនៃអគ្គនាយកដ្ឋានកសិកម្ម មន្ត្រីអង្គភាពពាក់ព័ន្ធផ្សេងទៀត និងផ្នែកឯកជន ក្នុងករណីចាំបាច់
- គ្រប់គ្រងការទទួល ការបញ្ជូន និងការចែកចាយលិខិត ការចេញលិខិតឧទ្ទិសនាម លិខិតបញ្ជាបេសកកម្ម កសាងរបាយការណ៍ និងការវាយតំលៃប្រសិទ្ធភាពការងារ
- ទំនាក់ទំនង និងសំរបសំរួលសាធារណៈ ផ្លាស់ប្តូរព័ត៌មាន ការងារសហប្រតិបត្តិការអន្តរស្ថាប័ន និងអន្តរជាតិ
- កសាងផែនការយុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍ផលិតកម្មកសិកម្ម រយៈពេលខ្លី មធ្យម វែង
- ប្រមូលទិន្នន័យ ព័ត៌មាន ស្ថិតិការងារដាំដុះ ប៉ាន់ស្មានទិន្នផល និង វិភាគវាយតំលៃគុណភាពស្បៀង និងផលដំណាំ ផ្សេងទៀត

- ទទួលខុសត្រូវ គ្រប់គ្រងការងារ ពាក់ព័ន្ធនឹងការរៀបចំផែនការ គណនេយ្យហិរញ្ញវត្ថុ ការបែងចែក និងថែរក្សាសម្ភារៈនិងបរិក្ខារ ទ្រព្យសម្បត្តិផ្សេងៗ សន្តិសុខ សណ្តាប់ធ្នាប់ របស់អគ្គនាយកដ្ឋានកសិកម្ម
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ជូន ។

នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ២៩.-** នាយកដ្ឋានដំណាំស្រូវ មានភារកិច្ចដូចតទៅ:

- រៀបចំគោលនយោបាយ កសាងផែនការ គំរោង កម្មវិធីអភិវឌ្ឍន៍ផលិតកម្មដំណាំស្រូវ ក្នុងទិសដៅបង្កើនផលិតភាព និងផលិតកម្មដំណាំស្រូវ ធានាបាននូវសន្តិសុខស្បៀងក្នុងប្រទេស បង្កើនចំណូលកសិករ បង្កើនបរិមាណនាំចេញអង្ករបានខ្ពស់
- កំណត់ទិសដៅ គ្រប់គ្រង និងជំរុញសកម្មភាពពិសោធន៍ស្រាវជ្រាវ នៃអង្គភាពពិសោធន៍ស្រាវជ្រាវក្រោមឱវាទ និងជំរុញសកម្មភាពផ្សព្វផ្សាយវិធីសាស្ត្រដាំដុះដំណាំស្រូវ និងអភិវឌ្ឍ ដោយសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងអង្គភាពមូលដ្ឋាន ស្របតាមលក្ខខណ្ឌភូមិសាស្ត្របរិស្ថាន ដល់កសិករ អង្គការកសិករ វិនិយោគិន និងវិស័យឯកជន
- ការរៀបចំលិខិតបទដ្ឋាន ច្បាប់គ្រប់គ្រងពូជដំណាំ ជាលេខាធិការអនុវត្តច្បាប់ពូជដំណាំ ជាភ្នាក់ងារអធិការកិច្ចពូជដំណាំស្រូវ និងទទួលខុសត្រូវការងារសាកល្បង វាយតំលៃគុណភាព កំណត់គោលការណ៍ និងគ្រប់គ្រងផលិតកម្ម និងការប្រើពូជដំណាំស្រូវ
- ចូលរួមក្នុងការរៀបចំស្តង់ដារស្រូវ អង្ករ ដើម្បីធានាលើកកំពស់គុណភាពផលិតផលកសិកម្ម
- ទំនាក់ទំនង និងសម្របសម្រួល ជំរុញការវិនិយោគរបស់វិស័យឯកជន ឱ្យបានចូលរួមវិនិយោគផលិតកម្មដំណាំស្រូវ និងការងារអភិវឌ្ឍផលិតកម្មដំណាំស្រូវ
- ទំនាក់ទំនង សហការ និងអនុវត្ត អនុសញ្ញា កិច្ចព្រមព្រៀង ដែលទាក់ទងនឹងផលិតកម្មដំណាំស្រូវ និងការគ្រប់គ្រងពូជដំណាំគ្រប់ប្រភេទ ក៏វិតថ្នាក់ជាតិ តំបន់ និង អន្តរជាតិ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន ប្រគល់ជូន ។

នាយកដ្ឋានដំណាំស្រូវ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៣០.-** នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ មានភារកិច្ចដូចតទៅ:

- រៀបចំគោលនយោបាយ កសាងផែនការ គំរោង កម្មវិធីអភិវឌ្ឍន៍ផលិតកម្មសាកវប្បកម្មនិងដំណាំរួមផ្សំ មានជាអាទិ៍ ដំណាំបន្លែ ឈើហូបផ្លែ រុក្ខជាតិលំអ ផ្កា ពោត សណ្តែក ល្ង... ក្នុងទិសដៅបង្កើនផលិតភាព និងផលិតកម្ម ធានាបាននូវសន្តិសុខស្បៀង បង្កើនចំណូលកសិករ និងជំរុញឱ្យបាននាំចេញ
- កំណត់ទិសដៅ គ្រប់គ្រង និងជំរុញសកម្មភាពពិសោធន៍ស្រាវជ្រាវរបស់អង្គភាពពិសោធន៍ស្រាវជ្រាវ ក្រោមឱវាទ និងជំរុញសកម្មភាពផ្សព្វផ្សាយវិធីសាស្ត្រដាំដុះដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំ និងអភិវឌ្ឍ ដោយសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងអង្គភាពមូលដ្ឋាន ដល់កសិករ អង្គការកសិករ វិនិយោគិន និងវិស័យឯកជន.
- រៀបចំលិខិតបទដ្ឋាន ច្បាប់គ្រប់គ្រងពូជដំណាំ ជាលេខាធិការអនុវត្តច្បាប់ពូជដំណាំ ជាភ្នាក់ងារអធិការកិច្ចពូជដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំ និងទទួលខុសត្រូវការងារសាកល្បង វាយតំលៃ កំណត់ គោលការណ៍

និងគ្រប់គ្រងផលិតកម្ម និងការប្រើពូជដំណាំ សាកវប្បកម្ម និងដំណាំរួមផ្សំ
- ចូលរួមក្នុងការរៀបចំស្តង់ដារផលិតផលសាកវប្បកម្ម និងដំណាំរួមផ្សំ ដើម្បីធានាលើកកំពស់គុណភាពផលិតផលកសិកម្ម
- ទំនាក់ទំនង និងសម្របសម្រួល ជំរុញការវិនិយោគរបស់វិស័យឯកជន ឱ្យបានចូលរួមវិនិយោគផលិតកម្មដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំ និងការងារអភិវឌ្ឍន៍វិស័យនេះ
- ទំនាក់ទំនង សហការ និងអនុវត្ត អនុសញ្ញា កិច្ចព្រមព្រៀង ដែលទាក់ទងនឹងផលិតកម្មដំណាំសាកវប្បកម្ម និងដំណាំរួមផ្សំ ក៏រិតថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ។
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ជូន ។

នាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៣១.-** នាយកដ្ឋានដំណាំឧស្សាហកម្ម មានភារកិច្ចដូចតទៅ:
- រៀបចំគោលនយោបាយ កសាងផែនការ គំរោង កម្មវិធីអភិវឌ្ឍន៍ផលិតកម្មដំណាំឧស្សាហកម្ម លើកលែងដំណាំកៅស៊ូ ក្នុងទិសដៅបង្កើនផលិតភាព និងផលិតកម្ម ធានាបាននូវការចូលរួមសន្តិសុខស្បៀង បង្កើនចំណូលកសិករ បង្កើនការងារដល់ប្រជាជន គាំទ្រដល់ការកែច្នៃក្នុងស្រុក និងជំរុញឱ្យមានការនាំចេញ
- កំណត់ទិសដៅ គ្រប់គ្រង និងជំរុញសកម្មភាពពិសោធន៍ស្រាវជ្រាវរបស់អង្គភាពពិសោធន៍ស្រាវជ្រាវ ក្រោមឱវាទ និងជំរុញសកម្មភាពផ្សព្វផ្សាយវិធីសាស្ត្រដាំដុះដំណាំឧស្សាហកម្ម លើកលែងតែដំណាំកៅស៊ូ និងអភិវឌ្ឍន៍ ដោយសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងអង្គភាពមូលដ្ឋាន ដល់កសិករ អង្គការកសិករ វិនិយោគិន និងវិស័យឯកជន
- រៀបចំលិខិតបទដ្ឋាន ច្បាប់គ្រប់គ្រងពូជដំណាំ ជាសេនាធិការអនុវត្តច្បាប់ពូជដំណាំ ជាភ្នាក់ងារអធិការកិច្ចពូជដំណាំឧស្សាហកម្ម និងទទួលខុសត្រូវការងារសាកល្បង វាយតំលៃ កំណត់គោលការណ៍ និងគ្រប់គ្រងផលិតកម្ម និងការប្រើពូជដំណាំឧស្សាហកម្ម
- ចូលរួមក្នុងការរៀបចំស្តង់ដារផលិតផលដំណាំឧស្សាហកម្ម ដើម្បីធានាលើកកំពស់គុណភាពផលិតផលកសិកម្ម
- ទំនាក់ទំនង និងសម្របសម្រួល ជំរុញការវិនិយោគរបស់វិស័យឯកជន ឱ្យបានចូលរួមវិនិយោគផលិតកម្មដំណាំឧស្សាហកម្ម និងការងារអភិវឌ្ឍវិស័យនេះ
- ទំនាក់ទំនង សហការ និងអនុវត្ត អនុសញ្ញា កិច្ចព្រមព្រៀង ដែលទាក់ទងនឹងផលិតកម្មដំណាំឧស្សាហកម្ម ក៏រិតថ្នាក់ជាតិ តំបន់ និង អន្តរជាតិ ។

នាយកដ្ឋានដំណាំឧស្សាហកម្ម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៣២.-** នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ មានភារកិច្ចដូចតទៅ:
- រៀបចំគោលនយោបាយ កសាងផែនការ គម្រោង កម្មវិធីអភិវឌ្ឍន៍ វិធានការកាត់បន្ថយការបាត់បង់ផលដំណាំ បង្កឡើងដោយសមាសភាពចង្រៃ គ្រប់គ្រងសារធាតុគីមីដែលប្រើប្រាស់ ក្នុងបំណងបង្ការ កំចាត់ សំលាប់ បណ្តេញអូសទាញ សំរបសំរួលការលូតលាស់ (និងអំពើផ្សេងទៀតនៃផ្នែកកសិកម្ម) សមាសភាពចង្រៃ និងភ្នាក់ងារ ឬសារធាតុជីវសាស្ត្រដែលប្រើប្រាស់ក្នុងគោលបំណងខាងលើ និងបំណង បង្កើនជីជាតិដីក្នុងទិសដៅបង្កើនផលិតភាព និងផលិតកម្មដំណាំ ដោយធានាបាននូវនិរន្តរភាពធនធានធម្មជាតិ និងជីវសាស្ត្រចំរុះ នៃបរិស្ថាន
- រៀបចំស្តង់ដារគុណភាពផលិតផលដំណាំ ប្រព័ន្ធគ្រប់គ្រងធានាគុណភាពសុវត្ថិភាពផលិតផលដំណាំ គោល

នយោបាយ កសាងផែនការ គំរោង កម្មវិធីអភិវឌ្ឍន៍គ្រប់គ្រង ធានាលើកកំពស់គុណភាព សុវត្ថិភាព ផលដំណាំតាំងដោយផ្តល់ ភាពជឿជាក់ក្នុងការធានាគុណភាព និង សុវត្ថិភាពផលដំណាំ ចំពោះអ្នកហូបចុក និងទីផ្សារ និងជំរុញការនាំចេញផលិតផលដំណាំ

- រៀបចំលិខិតបទដ្ឋាន ច្បាប់ និងជាសេវានីតិប្រតិបត្តិ ក្នុងការគ្រប់គ្រងការងារការពារដំណាំ ការងារ សុវត្ថិភាពអាហារជាផលិតផលកសិកម្ម និងការងារត្រួតពិនិត្យភូតគាមអនាម័យ ស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល និងកិច្ចព្រមព្រៀងផ្នែកអនាម័យនិងភូតគាមអនាម័យ នៃអង្គការពាណិជ្ជកម្មពិភពលោក
- កំណត់ទិសដៅ គ្រប់គ្រង និងជំរុញសកម្មភាពពិសោធន៍ស្រាវជ្រាវរបស់អង្គភាពពិសោធន៍ស្រាវជ្រាវ ក្រោមឱវាទ និងជំរុញសកម្មភាពផ្សព្វផ្សាយវិធានការណ៍ការពារដំណាំ ភូតគាមអនាម័យ និងវិធានការណ៍ផលិតកម្ម និងអភិវឌ្ឍ ដោយសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និង អង្គភាពមូលដ្ឋានដើម្បីលើកកំពស់គុណភាព និងសុវត្ថិភាពផលិតផល ដល់កសិករ អង្គការកសិករ វិនិយោគិន និងវិស័យឯកជន និងដើម្បីបង្កើនប្រាក់ចំណេញ និងចំណូលគ្រួសារ លើកកំពស់សុខមាលភាពប្រជាជន និងសម្របសម្រួល ជំរុញការនាំចេញកសិផល
- ជាសេវាគាំទ្រដល់អធិការកិច្ចពូជដំណាំ ដែលបំពេញនាទីជានិតិប្រតិបត្តិករ ដើម្បីត្រួតពិនិត្យរាល់សកម្មភាពដឹកជញ្ជូនពូជដំណាំឆ្លងកាត់ព្រំដែន ប្រទេស
- ទំនាក់ទំនង និងសម្របសម្រួល ជំរុញការវិនិយោគរបស់វិស័យឯកជន ឱ្យបានចូលរួមវិនិយោគសេវាគាំទ្រការងារការពារដំណាំ ភូតគាមអនាម័យ និងលើកកំពស់គុណភាពផលិតផលកសិកម្ម
- សេនាធិការបច្ចេកទេស និងផ្តល់សេវាលើការអន្តរាគមន៍កំចាត់សមាសភាពចង្រៃ វាយតំលៃសារធាតុគីមីដែលប្រើប្រាស់ក្នុងបំណងបង្ការ កំចាត់ សំឡាប់ បណ្តេញ អូសទាញ សំរបសំរួលការលូតលាស់ (និងអំពើដទៃទៀតនៃថ្នាំកសិកម្ម) សមាសភាពចង្រៃវាយតំលៃរាល់ភ្នាក់ងារឬសារធាតុជីវសាស្ត្រ ដែលប្រើប្រាស់ក្នុង គោលបំណងខាងលើ និងបំណងបង្កើនជីជាតិដី និងវាយតំលៃគុណភាពផលិតផលកសិកម្ម
- ទំនាក់ទំនង សហការ និងអនុវត្តអនុសញ្ញា កិច្ចព្រមព្រៀង ក៏រិតថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដែលមានទំនាក់ទំនង
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ជូន ។

នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៣៣.-** នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម មានភារៈកិច្ចដូចតទៅ:

- រៀបចំគោលនយោបាយ កសាងផែនការ គំរោងកម្មវិធីអភិវឌ្ឍន៍ វិធានការប្រើប្រាស់ធនធានដី និងកែលំអជីជាតិដី ក្នុងការងារផលិតកម្មដំណាំ ក្នុងទិសដៅបង្កើនផលិតភាពផលិតកម្មដំណាំ និងបង្កើនផលិតភាពនៃការប្រើប្រាស់ស្របតាមសក្តានុពលធនធានដី ដោយធានាបាននូវនិរន្តរភាពធនធានធម្មជាតិ និងជីវសាស្ត្រចំរុះ នៃបរិស្ថាន
- រៀបចំលិខិតបទដ្ឋាន ច្បាប់ និងជាសេវានីតិប្រតិបត្តិ ក្នុងការគ្រប់គ្រងធនធានដី និងការប្រើប្រាស់ដី និងមធ្យោបាយ ផ្សេងៗដើម្បីកែលំអជីជាតិដីកសិកម្ម ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបណ្តាអនុសញ្ញា កិច្ចព្រមព្រៀង ក៏រិតថ្នាក់ជាតិ តំបន់ និង អន្តរជាតិ ដែលមាន ទំនាក់ទំនង
- សិក្សា និងកសាងគោលការណ៍ណែនាំនៃការប្រើប្រាស់ដីកសិកម្ម ជាអាទិ៍មានការកំណត់តំបន់ដាំដុះតាមពីភ័ណ្ឌដីកសិកម្ម ការណែនាំក្នុងការប្រើជី និងការកែលំអជីជាតិដីទៅតាមប្រភេទដំណាំ ដី និងទៅតាមតំបន់ភូមិសាស្ត្រ

- កំណត់ទិសដៅ គ្រប់គ្រង និងជំរុញសកម្មភាពពិសោធន៍ស្រាវជ្រាវរបស់អង្គភាពពិសោធន៍ស្រាវជ្រាវ ក្រោមឱវាទ និង ជំរុញសកម្មភាពផ្សព្វផ្សាយវិធានការណ៍ប្រើប្រាស់ ធនធានដី ការប្រើប្រាស់ដីដើម្បីកែលំអជីជាតិដីក្នុងការងារផលិតកម្មដំណាំ និងអភិវឌ្ឍ ដោយសហការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងអង្គភាពមូលដ្ឋាន ដល់កសិករ អង្គការកសិករ វិនិយោគិន និងវិស័យឯកជន ក្នុងទិសដៅបង្កើនផលិតភាពផលិតកម្មដំណាំ និងបង្កើនផលិតភាព នៃការប្រើប្រាស់ស្របតាមសក្តានុពលធនធានដី
- ទំនាក់ទំនង និងសម្របសម្រួល ជំរុញការវិនិយោគរបស់វិស័យឯកជន ឱ្យបានចូលរួមវិនិយោគសេវាគាំទ្រការងារកែលំអជីជាតិដី
- សេនាធិការបច្ចេកទេស និងផ្តល់សេវាលើការ វាយតំលៃស្ថានភាពជីជាតិដី ស្ថានភាពដំណាំ ក្នុងតំរូវការជីជាតិដីដំណាំ ដែលបង្កឡើងដោយគុណភាពជីជាតិនិងសមាសភាគដី ជីគីមីរ៉ែ ជីគីមីសរីរាង្គ និងសារធាតុដែលប្រើប្រាស់ក្នុងគោលបំណងកែលំអជីជាតិដី
- ទំនាក់ទំនង សហការ និងអនុវត្ត អនុសញ្ញា កិច្ចព្រមព្រៀង ការិតថ្នាក់ជាតិ តំបន់ និង អន្តរជាតិ ដែលមានទំនាក់ទំនង
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ជូន ។

នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៣៤.-** នាយកដ្ឋានគ្រឿងយន្តកសិកម្ម មានភារកិច្ចដូចតទៅ:

- ស្រាវជ្រាវ និងកំណត់បែងចែកតំបន់ប្រើប្រាស់គ្រឿងយន្តកសិកម្ម ឧបករណ៍កសិកម្ម ម៉ាស៊ីនកសិកម្មតាមប្រភេទដី និងតាមមុខដំណាំ ដើម្បីអភិវឌ្ឍវិស័យកសិកម្ម
- រៀបចំគោលការណ៍ លិខិតបទដ្ឋានអំពីសក្តានុពល និងអំពីប្រសិទ្ធភាពគ្រឿងយន្តកសិកម្មក្នុងផលិតកម្មទាំងមូល
- ស្រាវជ្រាវ និងផ្តួចផ្តើមគំនិត ផលិត និងកែច្នៃឧបករណ៍កសិកម្ម និងមានវិធានការ និងមធ្យោបាយ ស្រាវជ្រាវដើម្បីបន្ថយការប្រើប្រាស់កំលាំងមនុស្សក្នុងការងារផលិតកម្មកសិកម្ម
- ណែនាំ និងផ្សព្វផ្សាយបច្ចេកទេសដល់អ្នកប្រើប្រាស់គ្រឿងយន្តកសិកម្ម ក្នុងផលិតកម្មកសិកម្ម ក្នុងនិងក្រោយពេលប្រមូលផលដើម្បីបង្កើន កែលំអផលិតកម្ម និងផលិតភាពកសិកម្ម
- ទំនាក់ទំនង និងសំរបសំរួលជំរុញការងារវិនិយោគរបស់វិស័យឯកជន ដើម្បីចូលរួមវិនិយោគសំភារៈ ឧបករណ៍គ្រឿងយន្តកសិកម្ម ដែលមានលក្ខណៈកាន់តែសមស្របទៅនឹងលក្ខខ័ណ្ឌនៃប្រទេសកម្ពុជា
- សេនាធិការបច្ចេកទេស និងផ្តល់សេវាលើការវាយតំលៃប្រសិទ្ធភាពនៃការប្រើប្រាស់គ្រឿងយន្តកសិកម្ម
- សិក្សា និងកំណត់សក្តានុពលធនធានទឹកសំរាប់ស្រោចស្រព ក្នុងករណីមានការចាំបាច់
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ជូន ។

នាយកដ្ឋានគ្រឿងយន្តកសិកម្ម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៣៥.-** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម មានភារកិច្ចដូចតទៅ:

- រៀបចំគោលនយោបាយ កសាងផែនការ គំរោងកម្មវិធីអភិវឌ្ឍន៍ និងចងក្រងអង្គការកសិករ សហគមន៍អភិវឌ្ឍកសិកម្ម អង្គការកសិដ្ឋានផលិតកម្មកសិកម្ម ក្នុងទិសដៅបង្កើនផលិតភាព ផលិតកម្ម និងផលិតកម្មដំណាំ និងបង្កើនប្រសិទ្ធភាពនៃការបញ្ជូនបច្ចេកទេស កសិកម្ម បង្កើនកទ្ធិពលចរចារទីផ្សារ និងលើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាកសិករ

- រៀបចំ ជំរុញ និងសម្របសម្រួលរាល់សកម្មភាពនៃការផ្សព្វផ្សាយ ការស្រាវជ្រាវ អភិវឌ្ឍន៍របស់វិស័យកសិកម្ម ដោយទំនាក់ទំនងរវាងអង្គភាពជំនាញមន្ទីរកសិកម្មខេត្ត ក្រុង មជ្ឈមណ្ឌលស្រាវជ្រាវ ផលិតករ កសិករ និងអង្គការវិជ្ជាជីវៈគ្រប់ជាន់ថ្នាក់
- កត់ត្រាជាប្រចាំនូវចំណេះដឹងដែលទទួលបានពីកសិករ និងពីលទ្ធផលនៃការស្រាវជ្រាវបច្ចេកទេសវិស័យកសិកម្ម នៅក្នុង និងក្រៅប្រទេស ហើយធ្វើការផ្សព្វផ្សាយចំណេះដឹងទាំងនោះដល់ប្រជាកសិករ
- សិក្សាស្រាវជ្រាវប្រមូលផ្តុំឯកសារបច្ចេកទេសកសិកម្ម សហការជាមួយអង្គភាពជំនាញនានា អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ដើម្បីរៀបចំអត្ថបទ ចងក្រងទស្សនាវដ្តី ព្រឹត្តិប័ត្រ គំនូរបកាព រឿងនិទានខ្លីៗ ខ្សែភាពយន្ត កាសែតវីដេអូ...ដើម្បីឱ្យការងារអប់រំផ្សព្វផ្សាយបច្ចេកទេសកសិកម្ម និងកែលំអវិធីសាស្ត្រផ្សព្វផ្សាយ
- ដឹកនាំការងារបង្ហាញ ផ្សព្វផ្សាយអំពីប្រភេទ បរិមាណ និងគុណភាពផលិតផលកសិកម្ម ដល់សាធារណជន ក្រោមរូបភាព ជាពិព័ណ ផ្សារលក់ផលិតផលកសិកម្ម ដើម្បីទាក់ទាញនិងបង្កើនទីផ្សារ
- តាមដានការអនុវត្ត និងការវាយតំលៃអំពីលទ្ធផលការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម សកម្មភាព និងប្រព័ន្ធផ្សព្វផ្សាយកសិកម្ម និងលើកវិធានការកែលំអជូនក្រសួង
- ចូលរួមសកម្មភាពអន្តរាគមន៍សង្គ្រោះដំណាំ និងស្តារការខូចខាតដំណាំដែលបង្កដោយគ្រោះធម្មជាតិ និងការរាត្បាតពីសំណាក់សមាសភាពចង្រៃ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ជូន ។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយ ចំនួនជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៣៦.-** មន្ទីរពិសោធន៍ជាតិកសិកម្ម មានតួនាទីជាមន្ទីរពិសោធន៍បង្អែកជាតិ លើការងារអភិវឌ្ឍន៍វិស័យផលិតកម្មកសិកម្ម មានភារកិច្ចដូចតទៅ:

- រៀបចំគោលនយោបាយ គសាងផែនការ គំរោងកម្មវិធីអភិវឌ្ឍន៍សមត្ថភាព និងភាពល្អនៃការវិភាគវាយតំលៃ ដើម្បីជាមូលដ្ឋានបង្អែក ប្រកបដោយប្រសិទ្ធភាព និងភាពទទួលយកបានជាអន្តរជាតិ ក្នុងការធ្វើសេចក្តី សំរេចចិត្តរបស់នាយកដ្ឋានជំនាញបច្ចេកទេសនៃ អគ្គនាយកដ្ឋានកសិកម្ម លើរាល់ពល់ការងារ ទទួលខុសត្រូវ និងឆ្លើយតបទៅ និងតំរូវការ ពីវិស័យឯកជន ក្នុងការងារអភិវឌ្ឍន៍ផលិតកម្មកសិកម្ម
- រៀបចំចងក្រងរាល់ពិធីសារវិភាគ និងធ្វើការវិភាគវាយតំលៃទាន់ពេល ក្នុងនាមជាសេនាធិការរបស់នាយកដ្ឋានជំនាញបច្ចេកទេសនៃអគ្គនាយកដ្ឋាន ដើម្បីផ្តល់ជាមូលដ្ឋានបង្អែកក្នុងការ ធ្វើសេចក្តីសំរេចចិត្ត រាល់ការងារទទួលខុសត្រូវ និងផ្តល់រាល់សេវាវិភាគតាមសំណើពីវិស័យឯកជន ក្នុងគោលបំណង អភិវឌ្ឍន៍ផលិតកម្មកសិកម្ម
- ទំនាក់ទំនង និងសំរបសំរួលជំរុញការវិនិយោគរបស់វិស័យឯកជន ដើម្បីចូលរួមវិនិយោគសេវាវិភាគ ដែលបំរើ ដល់កិច្ចអភិវឌ្ឍន៍ផលិតកម្មកសិកម្ម និងគ្រប់គ្រង ណែនាំលើកិច្ចដំណើការនៃមន្ទីរពិសោធន៍ទាំងនោះ
- ចូលរួមសកម្មភាពអន្តរាគមន៍សង្គ្រោះដំណាំ និងស្តារការខូចខាតដំណាំតាមការស្នើសុំពីនាយកដ្ឋានជំនាញ បច្ចេកទេស
- អនុវត្តភារកិច្ចផ្សេងទៀតដែលអគ្គនាយកដ្ឋានប្រគល់ជូន ។

មន្ទីរពិសោធន៍កសិកម្មជាតិ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់ ។

## ផ្នែកទី ៥

## អគ្គនាយកដ្ឋានកៅស៊ូ

**មាត្រា ៣៧.-** អគ្គនាយកដ្ឋានកៅស៊ូ មានបេសកកម្មដូចតទៅ:

- ធានាការអភិវឌ្ឍ និងការគ្រប់គ្រងវិស័យកៅស៊ូគ្រប់ផ្នែក ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចគ្រួសារ និងសង្គមសំដៅកាត់បន្ថយភាពក្រីក្រ
- លើកកំពស់គុណភាពផលិតផលកៅស៊ូ ដើម្បីធានាក្នុងការប្រកួតប្រជែងនៅទីផ្សារ តាមរយៈផ្តល់សេវាស្រាវជ្រាវ និងផ្ទេរបច្ចេកវិទ្យា ប្រកបដោយប្រសិទ្ធភាព
- អភិវឌ្ឍ និងគ្រប់គ្រងខ្សែសង្វាក់ផលិតកម្ម អាជីវកម្មកែច្នៃកៅស៊ូ សំដៅជំរុញពាណិជ្ជកម្មផលិតផលកៅស៊ូ ។

**មាត្រា ៣៨.-** អគ្គនាយកដ្ឋានកៅស៊ូ មានភារកិច្ច ធ្វើជាសេនាធិការឱ្យក្រសួង លើការងារ ដូចតទៅ:

- អនុវត្តយុទ្ធសាស្ត្រ គោលនយោបាយរបស់រាជរដ្ឋាភិបាល និងកម្មវិធីអភិវឌ្ឍ សំដៅធានាការអភិវឌ្ឍវិស័យកៅស៊ូនៅកម្ពុជា
- រៀបចំគោលនយោបាយ ចក្ខុវិស័យ គោលដៅ បេសកកម្ម និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍឧស្សាហកម្មកៅស៊ូសម្រាប់រយៈពេលមធ្យម និងវែង
- កសាងមូលដ្ឋានគតិយុត្តិ លិខិតបទដ្ឋាន ច្បាប់ ស្តីពីការគ្រប់គ្រងវិស័យកៅស៊ូ និងតាមដាន ធ្វើអធិការកិច្ច និងអនុវត្តច្បាប់ លើគ្រប់សកម្មភាពវិស័យកៅស៊ូនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ធានាការគ្រប់គ្រងគ្រប់សកម្មភាពកៅស៊ូរួមមានការដាំដុះ ការកែច្នៃ ការធ្វើពាណិជ្ជកម្មលើគ្រប់ផ្នែក នៃវិស័យកៅស៊ូ
- ជំរុញ និងអនុវត្តសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍនៅក្នុងការផលិត ការប្រើប្រាស់ជ័រកៅស៊ូ និងឈើកៅស៊ូ
- ផ្តល់សេវាណែនាំបច្ចេកទេស ដល់អ្នកដាំកៅស៊ូ
- ត្រួតពិនិត្យ និងតាមដានអំពីគុណភាពជ័រកៅស៊ូ រុក្ខសម្ភារៈដាំដុះ និងផលិតផលធ្វើពីជ័រកៅស៊ូ
- ពង្រីង និងបង្កើនយុទ្ធសាស្ត្រទីផ្សារអន្តរជាតិ សម្រាប់ឧស្សាហកម្មកៅស៊ូកម្ពុជា
- ប្រមូលផ្តុំទិន្នន័យ និងធនាគារស្ថិតិ ដែលទទួលបានពីគ្រប់ប្រភពចំការកៅស៊ូកសិ-ឧស្សាហកម្ម ចំការកៅស៊ូគ្រួសារ អាជីវករ និងម្ចាស់រោងចក្រកែច្នៃកៅស៊ូ
- រៀបចំផែនការ និងអនុវត្តការបណ្តុះបណ្តាលធនធានមនុស្ស តាមតម្រូវការ របស់វិស័យកៅស៊ូ
- ធ្វើទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារកៅស៊ូ និងអង្គការកៅស៊ូអន្តរជាតិនានា ក្នុងក្របខ័ណ្ឌការងារស្រាវជ្រាវនិងអភិវឌ្ឍ ការងារបច្ចេកវិទ្យាវិទ្យាសាស្ត្ររួម ដែលទាក់ទងដល់ពូជកៅស៊ូ ការប្រមូលផល ជម្ងឺកៅស៊ូ (ឫស ដើម មែក ស្លឹក) វិធានការប្រើប្រាស់ថ្នាំព្យាបាល ថ្នាំរំលួច ថ្នាំកំចាត់សត្វ និងស្មៅចង្រៃ
- ធ្វើជាប្រភព និងជាមជ្ឈមណ្ឌលពត៌មាន ស្តីពីឧស្សាហកម្មកៅស៊ូនៅកម្ពុជា តាមការបោះពុម្ពផ្សាយទស្សនាវដ្តី ព្រឹត្តិប័ត្រ កូនសៀវភៅ និងឯកសារពត៌មានផ្សេងៗ
- តាមដាន វាយតម្លៃ សម្របសម្រួល ណែនាំនិងគាំទ្រទិសចំពោះវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា សមាគមវិជ្ជាជីវៈកៅស៊ូ សមាគមអ្នកដាំកៅស៊ូ ម្ចាស់រោងចក្រកែច្នៃ ម្ចាស់ចំការកៅស៊ូកសិ-ឧស្សាហកម្ម

ពាណិជ្ជករ អ្នកនាំចេញកៅស៊ូ និងក្រុមហ៊ុន និងភ្នាក់ងារកៅស៊ូផ្សេងៗទៀត

- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ឱ្យ ។

អគ្គនាយកដ្ឋានចំការកៅស៊ូ ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៣៩.-** រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានកៅស៊ូ មាននាយកដ្ឋានចំនួន ៥ និងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាចំនួន ១ ដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម
- នាយកដ្ឋាន អភិវឌ្ឍន៍កៅស៊ូ
- នាយកដ្ឋាន ផែនការ-ហិរញ្ញវត្ថុ និងស្ថិតិ
- នាយកដ្ឋាន កែច្នៃផលិតផលកៅស៊ូ
- នាយកដ្ឋាន ទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ
- វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មានថ្នាក់ស្មើនាយកដ្ឋាន

**មាត្រា ៤០.-** នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម មានភារកិច្ចដូចខាងក្រោម៖

- រៀបចំគ្រប់គ្រង បែងចែក និងទទួលឯកសារចេញ-ចូល លិខិតឧទ្ទេសនាម លិខិតបញ្ជាបេសកកម្ម
- បូកសរុប និងធ្វើរបាយការណ៍ អំពីសកម្មភាពការងារទូទៅរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រង និងរៀបចំស្ថិតិមន្ត្រីរាជការ បណ្តុះបណ្តាលធនធានមនុស្ស
- រៀបចំបង្កើត រំសាយ ឬកែសម្រួលរចនាសម្ព័ន្ធ ក្រោមឱវាទអគ្គនាយកដ្ឋានចំការកៅស៊ូ
- គ្រប់គ្រងចលនៈ និងអចលនទ្រព្យ សន្និធិ និងបញ្ជីសារពើភ័ណ្ឌ
- រៀបចំតាក់តែងច្បាប់ និងលិខិតបទដ្ឋាននានា ស្តីពីការគ្រប់គ្រងវិស័យកៅស៊ូ
- ទទួលបណ្តឹងតវ៉ា ឬវិវាទ នៅតាមចំការកៅស៊ូនានា
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំប្រគល់ឱ្យ ។

នាយកដ្ឋានកិច្ចការទូទៅ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤១.-** នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ មានភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវអំពីសក្តានុពលនៃដីក្រហម និងដីប្រភេទផ្សេងទៀត ដែលមានលក្ខណៈសម្បត្តិសមស្របនឹងដំណាំកៅស៊ូ
- រៀបចំផែនការ និងកម្មវិធីអភិវឌ្ឍន៍កៅស៊ូ នៅទូទាំងប្រទេស
- ផ្តល់សេវាណែនាំ និងផ្សព្វផ្សាយអំពីលក្ខណៈបច្ចេកទេសក្នុងការដាំដុះ ការថែទាំ ការប្រមូលផល ការការពារជម្ងឺ (ឫស ដើម ស្លឹក) និងការបណ្តុះបណ្តាលបច្ចេកទេសចៀរជ័រ ដល់អ្នកដាំកៅស៊ូ
- រៀបចំគម្រោងបង្កើនគុណភាពដាំដុះកៅស៊ូគ្រួសារ
- តាមដាន និងវាយតម្លៃសកម្មភាពចំការកៅស៊ូគ្រួសារ ស្ថិតនៅក្នុង និងក្រៅគម្រោងអភិវឌ្ឍ
- ចូលរួម និងផ្តល់យោបល់ក្នុងការងារផ្តល់ដីសម្បទានសេដ្ឋកិច្ច និងសង្គមកិច្ច ដែលពាក់ព័ន្ធដល់ការអភិវឌ្ឍកៅស៊ូ
- ជំរុញសកម្មភាពសមាគមកសិករដាំកៅស៊ូ
- ផលិត និងបែងចែកកូនសម្ភារៈ ដែលមានគុណភាពខ្ពស់ ដល់អ្នកដាំកៅស៊ូ

- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំកាប់ដើមកៅស៊ូចាស់ៗ និងដាំដុះឡើងវិញ
- ប្រមូលផ្តុំទិន្នន័យ និងចងក្រងស្ថិតិ ដែលទទួលបានពីគ្រប់ប្រភពចំការកៅស៊ូកសិ-ឧស្សាហកម្ម ចំការកៅស៊ូគ្រួសារ អាជីវករ និងម្ចាស់រោងចក្រកែច្នៃកៅស៊ូទាំងអស់
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ឱ្យ ។

នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤២.-** នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ មានភារកិច្ចដូចខាងក្រោម:

- រៀបចំគោលនយោបាយ ចក្ខុវិស័យ គោលដៅ បេសកកម្ម និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍឧស្សាហកម្មកៅស៊ូសម្រាប់រយៈពេលមធ្យម និងវែង
- តាមដានការអនុវត្តផែនការ កម្មវិធីវិនិយោគ នៅលើវិស័យសម្បទានសេដ្ឋកិច្ច-សង្គមកិច្ច និងវាយតម្លៃលទ្ធផលដែលសម្រេចបាន
- រៀបចំគំរោងគ្រប់គ្រងថវិកា និងធ្វើរបាយការណ៍អំពីថវិកាចំណូល-ចំណាយ
- គ្រប់គ្រងសកម្មភាពចំណូលចំណាយក្នុងក្របខ័ណ្ឌជំនួយពីរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍ដំណាំកៅស៊ូ
- ពិនិត្យ និងជម្រុញការងារបង់ពន្ធចូលថវិកាជាតិ
- ផ្តល់លិខិតអនុញ្ញាតបង្កើតស្លាក់ការប្រមូលទិញជ័រកៅស៊ូ
- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផលិតផលកៅស៊ូ អនុផលពីដើមកៅស៊ូ ទាំងក្នុង និងក្រៅប្រទេស
- គ្រប់គ្រងគណនីប្រាក់កម្ចី ឬប្រាក់ជំនួយអន្តរជាតិ ដើម្បីអភិវឌ្ឍដំណាំកៅស៊ូ
- តាមដាន ប្រមូលផ្តុំពត៌មានសេដ្ឋកិច្ច ដែលទាក់ទងដល់ផ្នែកកៅស៊ូ
- តាមដាន និងវាយតម្លៃគម្រោងអភិវឌ្ឍកៅស៊ូគ្រួសារ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ឱ្យ ។
- នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និងស្ថិតិ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤៣.-** នាយកដ្ឋានទីផ្សារ និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចខាងក្រោម:

- ធ្វើទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ ទីភ្នាក់ងារកៅស៊ូ និងអង្គការកៅស៊ូអន្តរជាតិនានាក្នុងក្របខ័ណ្ឌការងារស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិជ្ជា វិទ្យាសាស្ត្រ
- ពង្រីកទីផ្សារថ្មីៗ សម្រាប់ផលិតផលជ័រ និងឈើកៅស៊ូ
- ជម្រុញ និងលើកទឹកចិត្តដល់ការនាំចេញផលិតផលជ័រ និងឈើកៅស៊ូ
- ប្រមូលផ្តុំ ចងក្រង និងផ្សព្វផ្សាយតម្លៃកៅស៊ូធម្មជាតិប្រចាំសប្តាហ៍ ខែ និងឆ្នាំ
- សិក្សាស្រាវជ្រាវ ផ្សព្វផ្សាយពត៌មានអំពីការផ្គត់ផ្គង់ និងតម្រូវការប្រើប្រាស់កៅស៊ូ អំពីនិន្នាការ នៃតម្លៃកៅស៊ូលើទីផ្សារ ក្នុង និងក្រៅប្រទេស ដើម្បីជម្រុញតម្លៃលក់ជ័រកៅស៊ូ
- ធ្វើសហប្រតិបត្តិការជាមួយអង្គការ និងដៃគូអន្តរជាតិ
- តាមដាន ត្រួតពិនិត្យ ស្រាវជ្រាវអំពីតម្លៃកៅស៊ូ ក្នុងស្រុក និងអន្តរជាតិ
- ពិនិត្យ និងសម្របសម្រួលថ្លៃលក់ផលិតផលកៅស៊ូ

- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ឱ្យ ។
- នាយកដ្ឋានទីផ្សារនិងសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាន នាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤៤.-** នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ មានភារកិច្ចដូចខាងក្រោម៖

- ផ្តល់សេវាបច្ចេកទេស ដល់រោងចក្រកែច្នៃកៅស៊ូគ្រប់ប្រភេទ និងឈើកៅស៊ូ
- គ្រប់គ្រងរោងចក្រ ត្រួតពិនិត្យគុណភាព ផលិតផលជ័រ និងឈើកៅស៊ូ
- តាមដាន ត្រួតពិនិត្យខ្សែសង្វាក់ផលិតកម្ម ជ័រ និងឈើកៅស៊ូ តាមលក្ខណៈបច្ចេកទេស
- សម្របសម្រួល និងលើកទឹកចិត្ត ដល់អ្នកវិនិយោគ ក្នុងការនាំចូលឧបករណ៍ សម្ភារៈ ខ្សែសង្វាក់ផលិតកម្ម និងវត្ថុធាតុគីមីផ្សេងៗ សម្រាប់បម្រើផលិតកម្ម
- ពិនិត្យ និងអនុញ្ញាតបង្កើតសិប្បកម្ម រោងចក្រកែច្នៃជ័រ និងឈើកៅស៊ូ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ឱ្យ ។

នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងអមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ៤៥.-** វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ និងសម្រេចរាល់សកម្មភាពស្រាវជ្រាវ ពិសោធន៍ សំដៅជម្រុញការអភិវឌ្ឍ លើគ្រប់ផ្នែកនៃដំណាំកៅស៊ូទូទៅ
- ចូលរួមក្នុងរាល់សកម្មភាព នៃការជម្រុញផ្នែកបច្ចេកទេស សុវឌ្ឍកម្ម នៃគុណភាពកៅស៊ូ និងតម្លៃផលិតកម្ម
- ទ្រទ្រង់ ដល់ការអនុវត្ត រាល់កម្មវិធីអភិវឌ្ឍដំណាំកៅស៊ូ តាមការសិក្សាអំពីលក្ខណៈវិនិច្ឆ័យ ការតាមដាន និងវាយតម្លៃលទ្ធផល តាមការរៀបចំសម្រួលឯកសារផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ តាមការធ្វើវិញ្ញាបនកម្ម ឡូតិ៍ពូជ
- ចាត់ចែងផ្តល់ពូជល្អៗតាមការបញ្ចូល សាកល្បង បង្កើត បង្កើន និងការផ្សព្វផ្សាយពូជ
- ចូលរួមក្នុងការធ្វើឱ្យមានតម្លៃនូវគុណភាពកៅស៊ូ តាមការគ្រប់គ្រងមន្ទីរពិសោធន៍ជាតិផ្នែកយថាប្រភេទ និងតាមការបង្កើតបទដ្ឋាន ស្តីពីគុណភាព
- ចាត់ចែងមធ្យោបាយ ធ្វើលក្ខណៈវិនិច្ឆ័យ និងវិភាគ
- ចូលរួមសកម្មភាពក្នុងការបណ្តុះបណ្តាលពត៌មាន ការផ្សព្វផ្សាយ និងការផ្ទេរបច្ចេកវិជ្ជាថ្មី
- ជាទូទៅ តាមការផ្តួចផ្តើមគំនិតរបស់ខ្លួនផ្ទាល់ ឬតាមសំណើរបស់ដៃគូក្នុងប្រទេស និងក្រៅប្រទេស នឹងចាត់ចែងគ្រប់សកម្មភាពដែលជាអត្ថប្រយោជន៍ដល់ការអភិវឌ្ឍប្រព័ន្ធកៅស៊ូ ព្រមទាំងកែលំអនូវការយល់ដឹងក្នុងវិស័យនេះ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលថ្នាក់ដឹកនាំអគ្គនាយកដ្ឋានប្រគល់ឱ្យ ។

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដឹកនាំដោយនាយកមួយរូប និងអមដោយនាយករងមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ៤៦.-** ការរៀបចំ និងការប្រព្រឹត្តិទៅរបស់រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល អគ្គនាយកដ្ឋានកសិកម្ម និងអគ្គនាយកដ្ឋានកៅស៊ូ ចាប់ពីថ្នាក់ ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៧.-** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤៨.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សូមឡាយហត្ថលេខា

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ជ័ន្ទ សារុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង និងរាជធានីភ្នំពេញ
- ដូចមានក្នុងមាត្រា ៤៨
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០០៨

អង្គការលេខ របស់អគ្គនាយកដ្ឋានចំការកៅស៊ូ



ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៧៥. អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០៨

អង្គការលេខ របស់អគ្គនាយកដ្ឋានកសិកម្ម



ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៧៧ . អនក្រ.បក.ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០០៨

អង្គការលេខ របស់រដ្ឋបាលព្រៃឈើ



ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៩៥ . អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៨

អង្គការលេខ របស់រដ្ឋបាលជលផល

ថ្នាក់ដឹកនាំរដ្ឋបាលជលផល

- នាយកដ្ឋាន កិច្ចការរដ្ឋបាល និងនីតិកម្ម
- នាយកដ្ឋាន អភិវឌ្ឍន៍វារីវប្បកម្ម
- នាយកដ្ឋាន អភិវឌ្ឍន៍សហគមន៍នេសាទ
- នាយកដ្ឋាន អភិរក្សជលផល
- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលសមុទ្រ

- នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និង សហប្រតិបត្តិការអន្តរជាតិ
- នាយកដ្ឋាន កិច្ចការជលផល
- នាយកដ្ឋាន បច្ចេកវិទ្យាកែច្នៃ និងគុណភាព
- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

អង្គភាពមូលដ្ឋាន